Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

86521

# ការដោះស្រាយសម្ពាធក្នុងប្រទេស និងការទទួលផលពីការពង្រឹងហិរញ្ញវត្ថុពិភពលោក

## បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា





## ប្រធានបទពិសេស:

### ការតម្លើងប្រាក់ខែសម្រាប់វិស័យសាធារណៈ

ធនាគារពិភពលោក

ខែ មេសា ឆ្នាំ ២០១៤

# ការដោះស្រាយសម្ពាធក្នុងប្រទេស និងការទទួលផលពីការពង្រឹង ហិរញ្ញវត្ថុពិភពលោក

## បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

ខែ មេសា ឆ្នាំ ២០១៤

**@ រក្សាសិទ្ធិគ្រប់យ៉ាង**

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះគឺជាផលិតផលរបស់ធនាគារពិភពលោក

របកគំហើញ ការបកស្រាយ និងការសន្និដ្ឋាននៅក្នុងបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះគឺជារបកគំហើញ ការបកស្រាយ និងការសន្និដ្ឋានរបស់បុគ្គលិកធនាគារពិភពលោក និងមិនប្រាកដថាឆ្លុះបញ្ចាំងពីទស្សនៈរបស់គណៈគ្រប់គ្រងរបស់ធនាគារ របស់ក្រុមប្រឹក្សាភិបាល ឬរដ្ឋាភិបាលដែលពួកគេតំណាងនោះទេ។

ធនាគារពិភពលោកមិនធានាភាពត្រឹមត្រូវនៃទិន្នន័យដែលមាននៅក្នុងវណ្ណកម្មនេះទេ។

# អារម្ភកថានិងសេចក្តីថ្លែងអំណរគុណ

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា (CEU) គឺជាផលិតផលមួយរបស់បុគ្គលិករបស់ធនាគារពិភពលោក។ ផលិតផលនេះត្រូវបានរៀបចំដោយ លោក លី សូដេត (Sodeth Ly) និងពិនិត្យឡើងវិញ និងកែសម្រួល ដោយលោក អេនរិកកេ អាល់ដាហ្ស ខារ៉ូល (Enrique Aldaz-Carroll) ផ្នែកកាត់បន្ថយភាពក្រីក្រ និងការគ្រប់គ្រងសេដ្ឋកិច្ច (PREM) ការិយាល័យធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា។ ក្រុមនេះធ្វើការក្រោមការដឹកនាំរបស់លោក ម៉ាសូ អេ វើហ្គិស (Mathew A. Verghis) សេដ្ឋវិទូជាន់ខ្ពស់និងជាប្រធានផ្នែកផ្នែកកាត់បន្ថយភាពក្រីក្រ និងការគ្រប់គ្រងសេដ្ឋកិច្ច(PREM)។ ក្រុមអ្នកនិពន្ធសូមថ្លែងនូវកតញ្ញូតាធម៌ចំពោះការប្រឹក្សានិងការណែនាំដែលផ្តល់ដោយលោក អ៊ូលរិក ហ្សាចៅ (Ulrich Zachau) នាយកប្រចាំប្រទេសកម្ពុជាសម្រាប់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក និងលោក អាឡាសាន់ សូ (Alassane Sow) នាយកគ្រប់គ្រងធនាគារពិភពលោកប្រចាំកម្ពុជា។

របាយការណ៍បច្ចុប្បន្នភាពនេះត្រូវបានផលិតរៀងរាល់ឆមាស ដើម្បីផ្តល់ពត៌មានថ្មីៗលើការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ របាយការណ៍បច្ចុប្បន្នភាពនេះត្រូវបានបោះពុម្ពផ្សាយ និងចែកចាយយ៉ាងទូលំទូលាយទៅកាន់អាជ្ញាធរកម្ពុជា សហគមន៍ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ក្រុមវិភាគនិងរៀបចំគោលនយោបាយ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសិក្សាស្រាវជ្រាវ ។ របាយការណ៍បច្ចុប្បន្នភាពនេះត្រូវបានកំណត់ពេលឲ្យស្របជាមួយនឹងការបោះពុម្ពផ្សាយបច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា ដោយផ្នែកកាត់បន្ថយភាពក្រីក្រ និងគ្រប់គ្រងសេដ្ឋកិច្ច អាស៊ីបូព៌ានៃធនាគារពិភពលោក។

យើងបានទទួលយោបល់ និងសំណើដ៏មានតម្លៃពីមិត្តរួមការងារផ្នែក PREM ពោលគឺលោក ដេផាក់ មិសស្រា (Deepak K. Mishra) ដែលបានផ្តល់យោបល់លើផ្នែកសេដ្ឋកិច្ចសកលផងដែរ និង យ៉ុង វ៉ាន់ឆា (Young Hwan Cha)។ យោបល់ និងសំណើល្អក៏បានទទួលផងដែរពីលោក អាលាន់ ដឺហោ (Alain W. D’Hoore) ដែលបានផ្តល់ព័ត៌មាន និងធាតុចូលស្តីពីប្រាក់ឈ្នួលប្រទេសឡាវ និងលោកស្រី លាអេប្រិល (Leah April) ដែលបានមានសន្តានចិត្ត ផ្តល់យោបល់លើតារាងបៀវត្សវិស័យសាធារណៈ។ យើងសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះយោបល់ និងសំណើច្បាស់លាស់ដែលផ្តល់ដោយ លោកស្រី រ៉ាឆាដា អនាន់តាវ៉ាស៊ីលប៉ា (Ratchada Anantavrasilpa) និង លោក ហេង ឌីណា (Dyna Heng) ផ្នែកវិស័យហិរញ្ញវត្ថុ និងឯកជន។ យើងមានសេចក្តីពេញចិត្តជាខ្លាំងចំពោះការគាំទ្រពី កញ្ញា គី លីនណា (Linna Ky) ដែលមានតួនាទីជាជំនួយការស្រាវជ្រាវ ធ្វើបច្ចុប្បន្នភាព តារាង និងរូបនានា ជួយរៀបចំទ្រង់ទ្រាយ CEU និងក្នុងការផ្តល់នូវការគាំទ្រផ្នែកផ្គត់ផ្គង់និងរដ្ឋបាលឥតខ្ចោះសម្រាប់រៀបចំនិងបោះពុម្ពផ្សាយ CEU នេះ។

យើងសូមថ្លែងនូវសេចក្តីដឹងគុណជាពន្លឹកចំពោះអាជ្ញាធរកម្ពុជា ពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ធនាគារជាតិនៃកម្ពុជាចំពោះកិច្ចសហប្រតិបត្តិការ និងការគាំទ្ររបស់ក្នុងការរៀបចំបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះ។

សម្រាប់ព័ត៌មានអំពីធនាគារពិភពលោកនិងសកម្មភាពរបស់ធនាគារនៅកម្ពុជាសូមទស្សនា www.worldbank.org/kh. ។

ដើម្បីដាក់បញ្ចូលទៅក្នុងបញ្ជីចែកចាយបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាតាមអ៊ីម៉ែលនិងឯកសារបោះពុម្ពផ្សាយពាក់ព័ន្ធ សូមទាក់ទង កញ្ញា គី លីនណា តាមអាស័យដ្ឋាន (lky@worldbank.org) ។ សម្រាប់សំណួរស្តីពីមាតិកានៃការបោះពុម្ពផ្សាយនេះ សូមទាក់ទងលោក ប៊ូ សារឿន (sbou@worldbank.org) ។

# តារាងមាតិកា


ខ្លឹមសារសង្ខេប ..... 1

ការអភិវឌ្ឍសេដ្ឋកិច្ចកាលពីពេលថ្មីៗ និងទស្សនវិស័យអនាគត ..... 4

វិស័យផលិតកម្ម ..... 4

កត្តាជំរុញនៃកំណើន ..... 4

អតិផរណានិងថ្លៃ ..... 6

ស្ថានភាពពាណិជ្ជកម្មក្រៅប្រទេស ..... 7

វិស័យរូបិយវត្ថុ ..... 8

បរិយាកាសសេដ្ឋកិច្ចពិភពលោក និងផលប៉ះពាល់របស់វា ..... 11

លំហសារពើពន្ធ ..... 13

និរន្តរភាពបំណុល ..... 15

សារគន្លឹះ ..... 16

ប្រធានបទពិសេស៖ ការតម្លើងប្រាក់ខែក្នុងវិស័យសាធារណៈ ..... 18

ទំហំមុខងារសាធារណៈរបស់ប្រទេសកម្ពុជា ..... 18

ចំណាយមុខងារសាធារណៈរបស់កម្ពុជា ..... 19

ការពង្រាយមន្ត្រីរាជការ និងការវិភាជថវិកាប្រាក់បៀវត្សតាមវិស័យ ..... 19

របាយមន្ត្រីរាជការនិងថវិកានៅថ្នាក់ខេត្តនិងនៅថ្នាក់កណ្តាល ..... 20

សេចក្តីសន្និដ្ឋាន ..... 23

ឧបសម្ព័ន្ធៈសូចនាករសំខាន់ៗនៅប្រទេសកម្ពុជា ..... 25

# ខ្លឹមសារសង្ខេប

**សេដ្ឋកិច្ចកម្ពុជាមានភាពធន់ទប់ទល់បាននឹង សម្ពាធក្នុងស្រុក ថែមទាំងបានរក្សាកំណើនខ្ពស់ ទៀតផង ដែលនេះត្រូវបានជំរុញដោយម៉ាស៊ីន កំណើនសេដ្ឋកិច្ចមានតាំងពីមុនមកដល់សព្វថ្ងៃនេះ។** កំណើនសេដ្ឋកិច្ចរបស់កម្ពុជាត្រូវប៉ាន់ស្មានថាបានខ្ពស់បំផុតសំរាប់ ៦ឆ្នាំចុងក្រោយនេះ គឺ ប្រហែល៧,៥ភាគរយនៅឆ្នាំ2013 ទោះបីជាមានភាពមិនប្រាកដប្រជាផ្នែកនយោបាយ និង ភាពរឹករវផ្នែកពលកម្មក៏ដោយ។ កំណើននេះត្រូវបាននាំមុខដោយការនាំចេញសម្លៀកបំពាក់ ដែលកំពុងបន្ថែមល្បឿន និង ផ្នែកទេសចរបន្តការកើនឡើង។ គាំទ្រដោយសេដ្ឋកិច្ចពិភពលោកដែល រឹងមាំជាងមុន ការនាំចេញសម្លៀកបំពាក់គិតជា តម្លៃបង្កើនល្បឿនថែមទៀត ដែលកើនឡើងដល់ 17,6 ភាគរយក្នុងឆ្នាំ 2013 ប្រៀបនឹង 7ភាគរយ ក្នុងឆ្នាំ2012 ទោះបីជាមានការខាតបង់ខ្លះៗ ដោយសារភាពមិននឹងនរផ្នែកទីផ្សារពលកម្ម ក៏ ដោយ។ វិស័យទេសចរណ៍នៅតែបន្តកំណើនខ្ពស់ ជាមួយនិងការមកដល់នៃភ្ញៀវទេសចរកើនដល់ 4,2លាននាក់ ហើយប្រទេសចិនបានក្លាយជា ប្រទេសប្រភពភ្ញៀវទេសចរណ៍លេខ2 សម្រាប់កម្ពុជានៅឆ្នាំ2013 ដែលឆ្នាំ2012ប្រទេសកូរ៉េខាង ត្បូងជាប្រទេសលេខ២។ ទឹកជំនន់រដូវវស្សាឆ្នាំកន្លងទៅ ជាភព្វសំណាងបណ្តាលអោយ មានការ ខូចខាតតិចតួច ផលិតកម្មស្រូវ។

**វិស័យទូទាត់ក្រៅប្រទេស បានប្រសើរជាងមុន ដោយសារតែ ការនាំចូលមានកំណើនយឺត ព្រោះតំរូវការក្នុង ស្រុកបានបន្ថយល្បឿន។** ការប៉ះពាល់ជាអវិជ្ជមាននៅក្រោយការបោះឆ្នោតបាន បន្ថយល្បឿនការនាំចូលនៅពេលដែលការនាំចេញបានបង្កើនល្បឿន។ ដូចបាននេះរួមចំណែកបាន ធ្វើអោយឱនភាពគណនីចរន្តបានរួមតូច (មិនគិតការផ្ទេរផ្លូវការ) ថយមកត្រឹម 9,4ភាគរយនៃផសសនៅឆ្នាំ2013 បើធៀបនឹង10,1 ភាគរយនៃ ផសសនៅឆ្នាំ2012។ រំហូរវិនិយោគផ្ទាល់ បរទេសសុទ្ធ នៅតែបន្តទាបជាងកម្រិតខ្ពស់បំផុត ក្នុងឆ្នាំ2012។ ទុនបម្រុងអន្តរជាតិដុលបានកើនឡើងបន្តិចដល់ប្រមាណ 3,6ពាន់លានដុល្លារ អាមេរិក ឬ ដែលអាចធានា ការនាំចូលបាន 3,8ខែក្នុងឆ្នាំ2013 បើប្រៀបធៀបនឹង 3,5ពាន់លាន ដុល្លាអាមេរិកក្នុងឆ្នាំ2012។ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកនៅតែមានស្ថិរភាព ដែលនាំអោយមានការធ្លាក់ចុះនៃអត្រាប្តូរប្រាក់ពិត។

**អតិផរណាបន្តកើនឡើងបន្តិចតែនៅតែទាប។**នៅពេលដែលថ្លៃទំនិញឧបភោគបរិភោគដែលជាតម្រូវការជាចំបាច់នៅតែមានស្ថិរភាព សម្ពាធអតិផរណាកំពុងកើនបន្តិចម្តងៗដោយសារការងើបឡើងថ្មីៗនេះ នៃតម្លៃមុខទំនិញម្ហូបអាហារមួយចំនួន។ អតិផរណាកើនដល់ ៤,៧ ភាគរយ នៅចុងឆ្នាំ2013 បើធៀបនឹងឆ្នាំ2012ដែលពេល នោះវានៅមានកំរិតតែ ២,៥ភាគរយប៉ុណ្ណោះ។ អតិផរណាត្រូវបានព្យាករថានៅក្នុងកម្រិតពាក់កណ្តាលលេខមួយខ្ទង់ក្នុងកំឡុងរយះពេលខ្លី។

**ភាពស៊ីជំម្រៅផ្នែកហិរញ្ញវត្ថុនៅតែបន្ត ប៉ុន្តែគំលាតរវាងអត្រាកំណើននៃឥណទាន និងប្រាក់បញ្ញើកើនឡើង ធ្វើអោយសន្ទនីយភាពរបស់ធនាគារថយចុះ។** កំណើនប្រាក់បញ្ញើរបស់វិស័យឯកជនមានល្បឿនយឺតជាងមុន នៅពេលដែលកំណើននៃឥណទាននៅតែខ្ពស់។ ប្រាក់បញ្ញើរបស់វិស័យឯកជនធ្លាក់ចុះបន្ទាប់ពីបោះឆ្នោតហើយ ប៉ុន្តែបានងើបឡើងវិញនៅខែវិច្ឆិការ។ កំណើនប្រាក់បញ្ញើរបស់វិស័យឯកជន

ក្នុងឆ្នាំ 2013មាន 14,2ភាគរយថយចុះពី 25,2ភាគរយនៅឆ្នាំ2012។ ផ្ទុយទៅវិញកំណើននៃឥណទាននៅតែខ្លាំងក្លាកើនឡើង 26,6ភាគរយនៅឆ្នាំ2013 ថយចុះតិចតួចពីកំណើន 28,0ភាគរយក្នុងឆ្នាំ2012។ នេះធ្វើអោយហានិភ័យនៃប្រទេសកម្ពុជាកើនឡើង ដែលបណ្តាលមកពីសន្ទនីយភាពរបស់ធនាគារថយចុះពីព្រោះ អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើកើនដល់ 90ភាគរយ នៅចុងឆ្នាំ2013 ប្រៀបនឹង 80ភាគរយនៅចុងឆ្នាំ2012។ កំណើនរូបិយវត្ថុទូទៅក៏បន្ថយល្បឿន ដោយសារតែប្រាក់បញ្ញើជារូបិយប័ណ្ណកើនឡើងយឺតគឺមានកំណើន 4,6ភាគរយនៅឆ្នាំ2013 ឬ ដល់6,7ពាន់លានដុល្លារអាមេរិកបើប្រៀបធៀប នឹងកំណើន20,9ភាគរយនៅឆ្នាំ2012 ឬ 5,9ពាន់លានដុល្លាអាមេរិក។

**កំណើនចំណូលក្នុងស្រុករបស់រដ្ឋាភិបាលមិនសូវខ្លាំងក្លា ដែលបណ្តាលអោយឱនភាពសារពើពន្ធកើនឡើង។** ឱនភាពសារពើពន្ធ (រួមទាំងជំនួយឥតសំណង)ក្នុងឆ្នាំ២០១៣ត្រូវបានប៉ាន់ប្រមាណថាមាន ៣,៩ភាគរយនៃផសស លើសឆ្នាំ ២០១២ បន្តិច ដែលមាន៣,៣ភាគរយនៃផសស នឹងត្រូវបាន ហិរញ្ញប្បទានដោយថវិការពីខាងក្រៅ។ បន្ទាប់ពីការកើនឡើងយ៉ាងគំហុកក្នុងឆ្នាំ២០១២ កំណើនចំណូលក្នុងស្រុកមិនសូវខ្លាំងក្លា កើនចំនួន៨ភាគរយក្នុងឆ្នាំ២០១៣ ប្រៀបធៀបនឹង ២៧ភាគរយក្នុងឆ្នាំ ២០១២ ដោយសារ កំណើននៃចំណូលពីការនាំចូល និង ចំណូលមិនមែនសារពើពន្ធយឺត។ ក្នុងឆ្នាំ២០១៣ ចំណូល ក្នុងស្រុកត្រូវបានប៉ាន់ប្រមាណថានឹងមាន១៤,៨ភាគរយនៃផសស ទាបជាងចំណូលខ្ពស់បំផុត នៃ១៥,៣ភាគរយដែលប្រមូលបាននៅឆ្នាំ ២០១២។ ចំណាយសាធារណៈត្រូវបានរឹតត្បិត ក្នុងរង្វង់២១,៣ភាគរយនៃផសស ក្នុងឆ្នាំ២០១៣ ប្រហាក់ប្រហែលកំរិតនៅឆ្នាំ២០១២ដែរ។ ទន្ទឹមគ្នានេះ ប្រាក់សន្សំរបស់រដ្ឋាភិបាលកើនឡើងដល់ ៧៦០លានដុល្លាអាមេរិកក្នុងឆ្នាំ២០១៣ ពី៦៩០លានដុល្លារអាមេរិកពីឆ្នាំ២០១២។

**ចំណាត់ថ្នាក់ ភាពតានតឹងនៃបំណុលនៅតែទាប។**កាលវិភាគនិរន្តភាពបំណុល (DSA)ដែលធ្វើឡើង រួមគ្នារវាង ធានាគារពិភពលោក និង មូលនិធិរូបិយវត្ថុអន្តជាតិនៅឆ្នាំ2012 បង្ហាញថាចំណាត់ថ្នាក់ភាពតានតឹង នៃបំណុលនៅតែទាបជាមួយ នឹងសូចនាករបន្ទុកបំណុលនានា ត្រូវបានគ្រោង ថាទាបជាងកម្រិតគោល។ ស្រដៀងនឹងការវាយតម្លៃកាលពីឆ្នាំ2012 លទ្ធផលបង្ហាញថានិរន្តរនៃបំណុលនៅតែមានភាពផុយស្រួយចំពោះ កំណើនសេដ្ឋកិច្ច ការនាំចេញ និង វិបត្តិសារពើពន្ធ ដែលសឲ្យឃើញតម្រូវការកំណែទម្រង់រចនាសម្ព័ន្ធជាបន្ត ដើម្បីធ្វើពិពិធកម្មកំណើន និងកែលម្អការប្រមូលចំណូល។ ទំហំបំណុលបរទេសរបស់ប្រទេសកម្ពុជា (រួមទាំងបំណុលកកស្ទះ) មានចំនួន4,5ពាន់លានដុល្លារអាមេរិក ឬ 32ភាគរយនៃផលិតផលក្នុងស្រុកសរុប នៅចុងឆ្នាំ2012 និងត្រូវបានព្យាករថានឹងឡើងដល់ 5.1ពាន់លានដុល្លារអាមេរិក ឬ 32.8 ភាគរយ នៃផសស នៅចុងឆ្នាំ2013។

**ទស្សនវិស័យសម្រាប់ការទ្រទ្រង់កំណើនខ្ពស់ទំនងជាមានលក្ខណៈអំណោយផល ចំណែកឯកំណើនពិត សម្រាប់ឆ្នាំ 2014 ត្រូវបានព្យាករថា នឹងកើនឡើងដល់ 7,2 ភាគរយ ដោយសារមានការរំពឹងទុកអំពីទំនុកចិត្តសាជាថ្មីនិងអំពី ស្ថិរភាពនយោបាយទ្រទ្រង់ ដោយការពង្រឹង ការងើបឡើងវិញនៃសេដ្ឋកិច្ចនៅក្នុងប្រទេសអភិវឌ្ឍន៍នានា។** កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថានឹងកើនពី ២,៤ភាគរយក្នុងឆ្នាំ២០១៣ ទៅ៣,២ភាគរយក្នុងឆ្នាំ២០១៤ ឆ្លុះបញ្ចាំង៩ពីកំណើនខ្លាំងជាងមុននៃសេដ្ឋកិច្ចប្រទេស

ចំណូលខ្ពស់។ តម្រូវការនៃប្រទេសចំណូលខ្ពស់ មានភាពរឹងមាំដែលជួយពង្រីកពាណិជ្ជកម្មពិភពលោក និងជម្រុញសន្ទុះនៃការនាំចេញប្រទេសកំពុងអភិវឌ្ឍ រួមទាំងប្រទេសកម្ពុជាផងដែរ។ ហានិភ័យដែលអាចអោយសេដ្ឋកិច្ចធ្លាក់ចុះរួមមាន ភាពចលាចលផ្នែកការងារដែលអាចកើតឡើងសារជាថ្មីនិងការថយចុះនៃកំណើនសេដ្ឋកិច្ចប្រទេសចិន។

**ចំណាត់ការអោយបានសមស្របចំពោះ សម្ពាធ ខាងក្នុងដើម្បីទទួលផលពីការប្រសើរឡើងថែមទៀតនៃបរិដ្ឋានសេដ្ឋកិច្ចពិភពលោក និងគាំពារ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។** ដោះស្រាយភាពរំជើបរំជួលខាងផ្នែកពលកម្ម ដោយចរចារប្រាក់បៀវត្ស ប្រកបដោយជោគជ័យផ្តល់ផលប្រយោជន៍ទាំងសងខាងនិយោជិក និងក្រុមហ៊ុន។ ដោយសារតែប្រទេសកម្ពុជាមានដុល្លារូបិនីយកម្មខ្ពស់ ការកសាងលំហសារពើពន្ធ (Fiscal Space) ដោយបង្កើនការប្រមូលចំណូលក្នុងស្រុកជាការចាំបាច់សំរាប់ជាឧបករណ៍គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏មានប្រសិទ្ធភាព សំរាប់ទប់ទល់នឹងវិបត្តិដែលអាចកើតឡើង។ ដូចគ្នាដែរកែលំអបន្ថែមការគ្រប់គ្រងធនាគារ នឹងពង្រឹងថែមទៀតនៃវិស័យហិរញ្ញវត្ថុ។ ពង្រឹងសមាហរណកម្មក្នុងតំបន់ និងអនុញ្ញាតអោយកម្ពុជាទទួលផលប្រយោជន៍ច្រើនទៀតពីការលូតលាស់ដ៏ខ្លាំងក្លាទូទាំងតំបន់នៃប្រទេសនានាក្នុងសហគមប្រជាជាតិអាស៊ីអាគ្នេយ៍។

**ទោះបីជាកម្ពុជាមានលំហសារពើពន្ធ (Fiscal Space)សំរាប់តម្លើងបៀវត្សដល់វិស័យសារធារណៈក៏ដោយវិធានការប្រុងប្រយ័ត្ន ក្នុងការតម្លើងប្រាក់បៀវត្សគឺប្រសើរបំផុត។** ថវិការឆ្នាំ2014 រំពឹងនឹងតម្លើងប្រាក់បៀវត្សដល់ 45ភាគរយនៃចំណាយចរន្តពី 40ភាគរយក្នុងឆ្នាំ2013។ ធ្វើដូចនេះឆ្លុះបញ្ចាំងនៃការតម្លើងការចំណាយប្រាក់បៀវត្សប្រមាណ 0,5ភាគរយនៃផសស គឺឡើងដល់5,5ភាគរយនៃផសស ពី5ភាគរយ នៃផសសក្នុងឆ្នាំ2013។ បទពិសោធន៍អន្តរជាតិបង្ហាញពីកត្តាបីសំខាន់ៗ ក្នុងការកំណត់ការតម្លើងប្រាក់បៀវត្ស។ ទីមួយ ភាពទ្រទ្រង់បាននៃសារពើពន្ធ ទីពី តំរូវការនៃការធ្វើអោយប្រសើរឡើងនយោបាយការចាត់ចែងធនធានមនុស្ស ដើម្បីបង្កើនផលិតភាព និងទីបីថ្លឹងថ្លែងអោយបានសមស្របអំពីការតម្លើងប្រាក់បៀវត្ស និងចំណាយអទិភាពដទៃទៀត ដូចជាការចំណាយលើវិស័យសង្គម និងចំណាយសំរាប់ថែទាំ និងជួសជុល។

# ការអភិវឌ្ឍសេដ្ឋកិច្ចកាលពីពេលថ្មីៗ និងទស្សនវិស័យអនាគត




រូបលេខ 1 ការងើបបឡើងវិញនៃវិស័យកាត់ដេរនាំមកនូវកំណើនពិតក្រោយពេលមាន

កំណត់សំគាល់: e = ប៉ាន់ស្មាន p= ព្យាករណ៍

ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិនិងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

## វិស័យផលិតកម្ម

### *កត្តាជំរុញនៃកំណើន*

**កំណើនសេដ្ឋកិច្ចមានភាពរឹងមាំទោះបីជាផលប៉ះពាល់អវិជ្ជមាននៃភាពមិនប្រាកដប្រជា ផ្នែកនយោបាយចាប់តាំងការបោះឆ្នោតសកលពីខែកក្កដាឆ្នាំ 2013 និងភាពចលាចលផ្នែកការងារឆ្ពោះទៅដំណាច់ឆ្នាំ 2013 ក្តី[1]។** ដោយសារបរិយាកាសសេដ្ឋកិច្ចក្រៅប្រទេសល្អប្រសើរ កំណើនពិតត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់ 7,4 ភាគរយនៅឆ្នាំ 2013 កំណើនភាគច្រើនបានមកពីវិស័យកាត់ដេរសម្លៀកបំពាក់ និងទេសចរណ៍។ ទោះបីជាទទួលរងការខាតបង់មួយចំនួនដោយ សារតែភាពចលាចលផ្នែកការងារក្តី វិស័យកាត់ដេរ ជំនះបាននូវការជំរុញការនាំចេញរបស់ខ្លួនបន្ថែមទៀត គឺកើនឡើងពី 7.0 ភាគរយនៅចុងឆ្នាំ 2012 ទៅ 17,6 ភាគរយ ក្នុងឆ្នាំ 2013 ដោយទទួលអត្ថប្រយោជន៍យ៉ាងច្រើន ពីការអនុគ្រោះផ្នែកពាណិជ្ជម្មលើគោលនយោបាយ" អ្វីគ្រប់យ៉ាងលើកលែងតែអាវុធ (EBA)" របស់សហភាពអឺរ៉ុប និងការងើបឡើងវិញ នៃទីផ្សារសហរដ្ឋអាមេរិក (រូបលេខ 2)[2]។ ជាលទ្ធផល ការរួមចំណែកនៃវិស័យឧស្សាហកម្ម ចំពោះកំណើនផលិតផលក្នុងស្រុកសរុបកើនឡើងពី 2.6 ភាគរយនៅឆ្នាំ 2012 ដល់លើសពី 3.0 ភាគរយ នៅឆ្នាំ 2013[3]។




រូបលេខ 2 ការនាំចេញសម្លៀកបំពាក់មានចំនួនតិចតួចនៅឆ្នាំ 2012 កំពុងមានចលករកើនឡើងនៅឆ្នាំ 2013

សំគាល់: YTD = ពីដើមឆ្នាំដល់បច្ចុប្បន្ន RHS = មាត្រដ្ឋានខាងស្តាំ 12 mma = មធ្យមភាព 12 ខែ

ប្រភព: អគ្គនាយកដ្ឋានគយនិងរដ្ឋាករ

---

1 ភាពចលាចលផ្នែកការងារក្នុងខែធ្នូឆ្នាំ2013-ដើមខែមករា2014 ទាមទារតម្លើងប្រាក់ឈ្នួលអប្បរមាទ្វេដងពី80ដុល្លារអាមេរិកដល់160 ដុល្លារអាមេរិកចំពោះវិស័យកាត់ដេរនិងស្បែកជើង(ប៉ុន្តែចុងក្រោយត្រូវបានដោះស្រាយត្រឹម100ដុល្លារអាមេរិក )បង្ខំឲ្យសមាគមនិយោជកបញ្ជូនលិខិតពីរច្បាប់កាលពីថ្ងៃទី2ខែមករាឆ្នាំ2014។លិខិតមួយច្បាប់ត្រូវបានផ្ញើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសុំឲ្យបញ្ជាក់នីតិវិធីនិងសុំឲ្យសម្រួលការនាំចេញបន្តក្រណាត់ សាច់ក្រណាត់កាត់រួច ផលិតផលពាក់ កណ្តាលសម្រេច និងផលិតផលសម្រេចមិនទាន់វេចខ្ចប់ ព្រមទាំងសម្ភារៈបរិក្ខាររោងចក្រទៅកាន់ប្រទេសដទៃ។ លិខិតមួយច្បាប់ទៀតបញ្ជូនទៅក្រសួងការងារជូនដំណឹងអំពីការបន្តពន្យារពេលដំណើរការរោងចក្រកាត់ដេរសម្លៀកបំពាក់។

2 សមាគមកាត់និយោជកនៅកម្ពុជា (GMAC) ត្រូវបានរាយការណ៍ថាបានប៉ាន់ប្រមាណនៅដើមខែមករាឆ្នាំ 2014 ថាភាពចលាចលរបស់កម្មករក្នុងការទាមទារប្រាក់ឈ្នួលអប្បបរមា 160 ដុល្លារអាមេរិកក្នុងមួយខែ (ជាជាង 100 ដុល្លារអាមេរិកក្នុងមួយខែដែលផ្តល់ដោយសមាគម) ធ្វើឲ្យរោងចក្រកាត់ដេរខាតបង់ចំណូលពីការលក់ចំនួន 200 លានដុល្លារអាមេរិក និងខាតបង់ប្រាក់ចំណូល 70 លានដុល្លារអាមេរិក។

3 ការវិភាគលើផលិភាពពលកម្មមិនអាចធ្វើទៅបានដោយខ្វះទិន័យ។

លើមូលដ្ឋានថ្លៃថេរឆ្នាំ 2000 វិស័យឧស្សាហកម្ម មានចំណែកស្មើនឹង 28.9 ភាគរយនៃ ផសស ក្នុងឆ្នាំ 2012 មានកម្រិតខ្ពស់ជាងចំណែកនៃវិស័យកសិកម្មដែលស្មើនឹង 25.6 ភាគរយនៃផសស (រូបលេខ 3)។

រូបលេខ 3 អត្រាភាគរយនៃវិស័យឧស្សាហកម្មមានចំណែកធំជាងវិស័យកសិកម្មចាប់តាំងពីឆ្នាំ 2011 មក




សំគាល់: e = ប៉ាន់ស្មាន f = ព្យាករណ៍

ប្រភព: វិទ្យាស្ថានជាតិស្ថិតិនិងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

វិស័យទេសចរណ៍បន្តគន្លងកំណើនខ្ពស់ ជាមួយនឹងការមកដល់របស់ភ្ញៀវទេសចរ កើនឡើងដល់ 4,2 លាននាក់នៅឆ្នាំ 2013 មានកំណើន 17,5 ភាគរយ ធៀបនឹង 24 ភាគរយ នៅចុងឆ្នាំ 2012 (រូបលេខ 4)។ ការមកដល់របស់ភ្ញៀវទេសចរតាមផ្លូវអាកាសមានភាពប្រសើរឡើង ដោយមានកំណើន 17,2 ភាគរយ ក្នុងឆ្នាំ 2013 ធៀបនឹងត្រឹមតែ 16,2 ភាគរយក្នុងឆ្នាំ 2012 [4]។ ប្រទេសវៀតណាម ចិន និងកូរ៉េខាងត្បូងនៅតែជា ប្រភពទីផ្សារសំខាន់ចំពោះភ្ញៀវទេសចរអន្តរជាតិមកកម្ពុជា ដែលរួមចំណែកជាង40ភាគរយ នៃចំនួនភ្ញៀវទេសចរសរុប។ នៅឆ្នាំ2013ប្រទេសចិនបានវ៉ាដាច់ប្រទេសកូរ៉េខាងត្បូងក្លាយជាប្រភពទីផ្សារលំដាប់លេខពីរបន្ទាប់ពីប្រទេសវៀតណាម[5]។ ការរួមចំណែករបស់វិស័យសេវាកម្ម ត្រូវបានគេប៉ាន់ស្មានថាមានប្រមាណ 3ភាគរយ នៃកំណើនផលិតផលក្នុងស្រុកសរុបពិត នៅឆ្នាំ2013 ស្រដៀងគ្នាទៅនឹងការចូលរួមចំណែកនៅឆ្នាំ2012ដែរ។ ទឹកជំនន់រដូវវស្សាក្នុងឆ្នាំ 2013 បណ្តាលឱ្យមានការខូចខាតខ្លះ ដល់ផលិតកម្មកសិកម្មហើយ វិស័យកសិកម្មត្រូវបានប៉ាន់ស្មានថា រួមចំណែកប្រហែលជិត 1ភាគរយ ចំពោះកំណើនពិតនៅឆ្នាំ 2013[6] ។ កំណើនជាវិជ្ជមានក្នុងវិស័យកសិកម្ម ពឹងផ្អែកយ៉ាងខ្លាំងនៃការកើនឡើងផលិតភាព ដោយសារកសិករចាប់ផ្តើមប្រើប្រាស់ជីដើម្បីដំណាំ និងបច្ចេកទេសដាំដុះទំនើប។

4 យោងតាមទស្សនាវដ្តីអាកាសយានដ្ឋានកម្ពុជា, ច្បាប់លេខទី 2 ខែកុម្ភៈ 10, 2014 ប្រទេសកម្ពុជាបានក្លាយជាផ្នែកមួយនៃទីផ្សាររីកលូតលាស់លឿនបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ មានកំណើនអ្នកដំណើរ 18 ភាគរយ សម្រាប់ពីរឆ្នាំជាប់គ្នាក្នុងឆ្នាំ 2013 ។ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញនិងសៀមរាបនឹងអនុវត្តគម្រោងពង្រីកស្ថានីយដើម្បីឆ្លើយតបនឹងកំណើនអ្នកដំណើរដែលបានរំពឹងទុក។ ការងារសាងសង់បានចាប់ផ្តើមនៅក្នុងស្ថានីយនៃអាកាសយានដ្ឋានទាំងពីរ។ នៅពេលបញ្ចប់ នៅចុងឆ្នាំ 2015 ឬដើមឆ្នាំ 2016 សមត្ថភាពរបស់អាកាសយានដ្ឋានទាំងពីរនឹងកើនឡើងទ្វេដងដល់ទៅ 5 លាននាក់ចំពោះអាកាសយានដ្ឋាននីមួយៗ។ នៅឆ្នាំ 2013 អាកាសយានដ្ឋានភ្នំពេញបានស្វាគមន៍អ្នកដំណើរចំនួន 2,39 លាននាក់ ខណៈពេលដែលអាកាសយានដ្ឋានសៀមរាបបានទទួល 2,66 លាននាក់ កើនឡើង 15 ភាគរយនិង 20 ភាគរយរៀងគ្នា។

5 យោងតាមសេចក្តីប្រកាសព័ត៌មានរបស់អង្គការទេសចរណ៍ពិភពលោករបស់សហប្រជាជាតិ ក្នុងខែមេសាឆ្នាំ 2013 អ្នកដំណើរចិនបានកើនឡើងពី 10 លាននាក់ក្នុងឆ្នាំ 2000 ដល់ 83 លាននាក់ក្នុងឆ្នាំ 2012 ។ ការចំណាយលើការធ្វើដំណើររបស់ចិននៅក្រៅប្រទេសបានកើនឡើងដល់ 102 ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ 2012 ក្លាយជាប្រទេសចំណាយធំជាងគេបំផុតនៅក្នុងវិស័យទេសចរណ៍អន្តរជាតិនៅទូទាំងពិភពលោក។ ប្រទេសចិនបានហក់ទៅលំដាប់ទីមួយ កើនលើសទាំងប្រទេសអាល្លឺម៉ង់ដែលចាយវាយច្រើនបំផុតនិងលំដាប់ទីពីរគឺសហរដ្ឋអាមេរិក (ទាំងពីរនេះចំណាយជិតស្មើ 84 ពាន់លានដុល្លារអាមេរិកនៅក្នុងឆ្នាំ2012)។លំនាំនៃការចាយវាយរបស់ទេសចរផ្សេងៗអាចខុសគ្នា ប៉ុន្តែវាហួសពីសមត្ថភាពរបស់របាយការណ៍នេះក្នុងការវិភាគឥទ្ធិពលរបស់ក្រុមទេសចរណ៍ប្រទេសនិមួយៗ មកលើសេដ្ឋកិច្ចកម្ពុជា។

6 កាលពីខែវិច្ឆិកាក្រសួងកសិកម្មបានឲ្យដឹងថាការខូចខាតដំណាំស្រូវដែលបណ្តាលមកពីទឹកជំនន់ថ្មីៗនេះមានទំហំ 128,421 ហិកតា ត្រូវជា 5 ភាគរយនៃផ្ទៃដីដាំដុះ

រូបលេខ 4 ទេសចរណ៍រឹងមាំទោះបីជាមានមិនសូវមានកំណើនខ្ពស់ដោយសារផលប៉ះពាល់

ចំនួនភ្ញៀវមកដល់ (YTD គិតជាលាននាក់ & Y/Y % នៃ 12mma (RHS)




ប្រភព:ក្រសួងទេសចរណ៍

**ទន្ទឹមនឹងនេះដែរ ផលប៉ះពាល់អវិជ្ជមានមកលើទំនុកចិត្តបានធ្វើឲ្យធ្លាក់ចុះ នូវតម្រូវការក្នុងស្រុក និងការធ្លាក់ចុះ នៃសកម្មភាពសាងសង់ និងអចលនទ្រព្យ។** ការធ្លាក់ចុះនៃគម្រោងវិនិយោគលើការសាងសង់ និងអចលនទ្រព្យដែលបានអនុម័តក្នុងឆ្នាំ2013 មានលក្ខណ:គួរឲ្យកត់សម្គាល់ (រូបលេខ 5) ។

រូបលេខ 5 ការធ្លាក់ចុះនៃការវិនិយោគលើវិស័យសំណង់និងអចលនទ្រព្យ

ទឹកប្រាក់វិនិយោគលើអចលនទ្រព្យ (YTD គិតជាពាន់លានដុល្លារនិងជា % នៃ RHS សរុប)




ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**កំណើនពិតរបស់ប្រទេសកម្ពុជាសម្រាប់ឆ្នាំ 2014 ត្រូវបានព្យាករថានឹងសម្រេចបាន 7,2 ភាគរយ អាស្រ័យលើការវិល ត្រឡប់ទៅកាន់ស្ថិរភាពនយោបាយនិងក្តីរំពឹងអំពីទំនុកចិត្តសាជាថ្មី។** ផ្តើមចេញពីការពង្រឹងសេដ្ឋកិច្ច របស់ប្រទេសអភិវឌ្ឍវិស័យកាត់ដេរវិលត្រឡប់មកកាន់ដំណើរការពេញលេញក្រោយការបញ្ចប់ភាពចលាចលផ្នែកការងារ ខណ:ពេលដែល វិស័យទេសចរណ៍គ្មានរងឥទ្ធិពលពីភាពចលាចលនេះ ហើយបន្តពង្រីកខ្លួន (កំណើនភ្ញៀវតាមជើងអាកាស កំពុងកើនឡើង) តាមរយ: ការហោះហើរដោយផ្ទាល់បន្ថែមទៀតដែលកំពុងត្រូវបានរៀបចំ។ ដូចដែលបានបង្ហាញក្នុងរូបលេខ 1 ខាងលើ ក្នុងអំឡុងពេលក្រោយវិបត្តិ កំណើនពិតមានអត្រាទាបជាងបណ្តាឆ្នាំមុនពេលមានវិបត្តិ ប៉ុន្តែហាក់ដូចជាស្របគ្នាជាមួយនឹងសក្តានុពលនៃកំណើន (រវាង7ទៅ8ភាគរយ)។ ទោះជាយ៉ាងណាក្តី ភាពចលាចលផ្នែកការងារដែលអាចកើតមានបន្ថែមទៀត ផលប៉ះពាល់អវិជ្ជមាននៃការធ្លាក់ចុះសេដ្ឋកិច្ចរបស់ប្រទេសចិនទាំងអស់នេះអាចបង្កជាហានិភ័យ។

## *អតិផរណានិងថ្លៃ*

**អតិផរណាកំពុងកើនឡើងបន្តិចម្តងៗ។** ខណ:ដែលសមាសភាគម្ហូបអាហារ គឺជាកត្តាជម្រុញចំបងនៃសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់របស់ប្រទេសកម្ពុជាមានចំណែក 43,3 ភាគរយ នៅក្នុងកន្ត្រកអតិផរណា ថ្លៃស្បៀងអាហារដែលមានស្ថិរភាព បន្តជួយកាត់បន្ថយអតិផរណា។ ជាទូទៅតម្លៃមុខទំនិញស្បៀងអាហារ ដូចជាអង្ករ និងត្រីមានស្ថិរភាព។ ប៉ុន្តែសម្ពាធអតិផរណាកំពុងកើនឡើងជាលំដាប់កាលពីពេលថ្មីៗ បណ្តាលមកពីការកើនតម្លៃមុខទំនិញស្បៀងអាហារមួយចំនួនពិសេស សាច់ មាន់ និងផ្លែឈើ។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់បានកើនឡើងដល់ 4,7 ភាគរយនៅចុងឆ្នាំ 2013 ធៀបនឹង 2,5 ភាគរយ ប៉ុណ្ណោះនៅចុងឆ្នាំ 2012 (រូបលេខ 6)។

រូបលេខ 6 អតិផរណានាំមុខដោយតម្លៃស្បៀងអាហារ នៅមានកម្រិតទាប

សមាសភាគអតិផរណារយៈពេល 12 ខែ (សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ)




ប្រភព:វិទ្យាស្ថានជាតិស្ថិតិ

**អតិផរណាត្រូវបានព្យាករថាមានកម្រិតត្រឹមពាក់កណ្តាលតួលេខខ្ទង់រាយមួយខ្ទង់ក្នុងដំណាក់កាលខ្លី។** ការឡើងថ្លៃប្រាក់ដុល្លារអាមេរិកជាមួយនឹងការបន្តរក្សាតម្លៃប្រាក់រៀល ទៅនឹងប្រាក់ដុល្លារអាមេរិកជាមធ្យោបាយទ្រទ្រង់ កម្រិតតម្លៃប្រាក់រៀលខណៈដែលអត្រាអតិផរណានៃបណ្តាប្រទេសនាំចូលចំបងរបស់កម្ពុជាមានស្ថិរភាព និងរឹតបន្តឹង (រូបលេខ 7 )។

រូបលេខ 7 សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់នៅកម្ពុជាស្របគ្នាជាមួយបណ្តាប្រទេសក្នុងតំបន់

អតិផរណាក្នុងតំបន់ ( % ប្រែប្រួលធៀបនឹងឆ្នាំមុន)




Source: Cambodian NIS, Vietnamese GSO, Thai MoC, Chinese NBS, and others.

## *ស្ថានភាពពាណិជ្ជកម្មក្រៅប្រទេស*

**ស្ថានភាពពាណិជ្ជកម្មក្រៅប្រទេស បានប្រសើរឡើង។** កំណើនការនាំចូលយឺត ជាចម្បងបណ្តាលមកពីការធ្លាក់ចុះតម្រូវការក្នុងស្រុក ចំណែកឯការបង្កើនការនាំចេញបាន រួមចំណែកដល់ការកាត់បន្ថយឱនភាពពាណិជ្ជកម្ម ដែលត្រូវបានគេប៉ាន់ស្មានថានឹងថយចុះប្រមាណជា 13.8 ភាគរយ នៃ GDP ក្នុងឆ្នាំ2012[7] ដល់ 12.8 ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ 2013 ។ ជាតួលេខដាច់ខាត ឱនភាពពាណិជ្ជកម្មត្រូវបានប៉ាន់ស្មានថានឹងកើនឡើងតិចតួចពី 1.94 នៅឆ្នាំ 2012 ដល់1.98ពាន់លានដុល្លារអាមេរិកនៅឆ្នាំ2013 (រូបលេខ ៨ )។

ប្រអប់លេខ 8 ការនាំចេញកើនឡើង ការនាំចូលធ្លាក់ចុះ នាំដល់ការកាត់បន្ថយឱនភាពពាណិជ្ជកម្ម

គិតជាលានដុល្លារអាមេរិក




ប្រភព: ធនាគារជាតិនៃកម្ពុជា និងការប៉ាន់ស្មាននិងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក

ដូចបានបង្ហាញនៅក្នុងរូបលេខ 9 ខាងក្រោម ការធ្លាក់ចុះនូវតម្រូវការក្នុងស្រុកចំពោះយានយន្តសាំង និងសម្ភារៈសំណង់បានកាត់បន្ថយកំណើននៃការនាំចូល។

7 ជញ្ជីងពាណិជ្ជកម្មស្មើនឹងទឹកប្រាក់នាំចេញសរុបដកទឹកប្រាក់នាំចូលសរុប។ ប្រសិនបើការនាំចេញសរុបធំជាងការនាំចូលសរុប ជញ្ជីងពាណិជ្ជកម្មមានលក្ខណៈវិជ្ជមាន ឬមានអតិរេកពាណិជ្ជកម្ម។ ប្រសិនបើនាំចេញសរុបតូចជាងនាំចូលសរុប ជញ្ជីងពាណិជ្ជកម្មមានលក្ខណៈអវិជ្ជមាន ឬឱនភាពពាណិជ្ជកម្ម។

**រូបលេខ 9** **ការធ្លាក់ចុះតម្រូវការក្នុងស្រុក ធ្វើឲ្យការនាំចូលធ្លាក់ចុះ**
ការនាំចូលយានយន្តនិងប្រេងឥន្ធនៈ
(ប្រែប្រួលជាមធ្យមរយៈពេល 12 ខែ ធៀបនឹងឆ្នាំមុន




ប្រភព: អគ្គនាយកដ្ឋានគយនិងរដ្ឋាករ

ជាលទ្ធផល ឱនភាពគណនីចរន្ត (មិនគិតប្រាក់បង្វែរផ្លូវការ) ត្រូវបានប៉ាន់ស្មានថានឹងធ្លាក់ចុះដល់ប្រហែល 9,4 ភាគរយ នៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ 2013 ធៀបនឹង 10.1ភាគរយ នៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ 2012[8] ។ បើគិតទាំងប្រាក់បង្វែរផ្លូវការ ឱនភាពគណនីចរន្តក៏មានភាពប្រសើរឡើង ពោលគឺធ្លាក់ចុះពី 5,8 ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ 2012 ដល់ 5,4 ភាគរយនៃផលិតផលក្នុងស្រុកសរុប នៅឆ្នាំ2013។ អតិរេកគណនីហិរញ្ញវត្ថុ(មូលធន)បន្តគ្របដណ្តប់ឱនភាពគណនីចរន្ត ធ្វើឲ្យមានជញ្ជីងទូទាត់វិជ្ជមានក្នុងអំឡុងក្រោយពេលមានវិបត្តិ (រូបលេខ 10)។

**រូបលេខ 10** **តុល្យភាពជារួមមានលក្ខណៈវិជ្ជមានដោយសារអតិរេកគណនីហិរញ្ញវត្ថុ(មូលធន) មានទំហំធំជាងឱនភាពគណនីចរន្ត**




ប្រភព:ធនាគារជាតិនៃកម្ពុជានិងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

ឱនភាពគណនីចរន្តនៅតែបន្តទទួលហិរញ្ញប្បទានយ៉ាងច្រើន ពីរំហូរចូលវិនិយោគផ្ទាល់ពីបរទេស ទោះបីជាក្នុងឆ្នាំ2013 រំហូរចូលនេះត្រូវបានប៉ាន់ប្រមាណថាស្ថិតនៅក្រោមកម្រិតខ្ពស់បំផុត នៃឆ្នាំ 2012 ក្តី (រូបលេខ 11) ។ ការណ៍នេះ ឆ្លុះឲ្យឃើញតួនាទីដ៏សំខាន់ នៃវិនិយោគផ្ទាល់ពីបរទេសក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច របស់ប្រទេសកម្ពុជា។

**រូបលេខ 11** **ឱនភាពគណនីចរន្តបានទទួលហិរញ្ញប្បទានពីវិនិយោគផ្ទាល់ពីបរទេស**




ប្រភព: ធនាគារជាតិនៃកម្ពុជា និងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

## វិស័យរូបិយវត្ថុ

**ផលប៉ះពាល់អវិជ្ជមានមកលើទំនុកចិត្តធ្វើឱ្យកំណើន (ឆ្នាំធៀបឆ្នាំ) ប្រាក់បញ្ញើវិស័យឯកជនធ្លាក់ចុះគួរឱ្យកត់សម្គាល់ ដោយថយចុះពី 25,2 ភាគរយ នៅចុងឆ្នាំ 2012 ដល់ 14,2 ភាគរយ គិតត្រឹមខែធ្នូឆ្នាំ 2013** (រូបលេខ 12 )។ ប្រាក់បញ្ញើក្នុងវិស័យឯកជនបានធ្លាក់ចុះ ក្នុងអំឡុងខែកក្កដា-សីហាឆ្នាំ 2013 ក្រោយការបោះឆ្នោតថយពី 6,5 ពាន់លានដុល្លារអាមេរិកក្នុងខែមិថុនាដល់ 5,9 ពាន់លានដុល្លារអាមេរិកនៅក្នុងខែសីហា ប៉ុន្តែបានកើនឡើងវិញក្នុងខែវិច្ឆិកាឆ្នាំ 2013 ។ ផ្ទុយទៅវិញ កំណើនឥណទាននៅតែខ្ពស់ គឺកើនឡើង 26,6 ភាគរយនៅឆ្នាំ 2013 ទាបជាងបន្តិចធៀបនឹងអត្រាកំណើន 28,0 ភាគរយ នៅចុងឆ្នាំ 2012 ។

[8] ឱនភាពគណនីចរន្ត(មិនគិតប្រាក់បង្វែរផ្លូវការ)ស្មើនឹងផលបូកនៃជញ្ជីងពាណិជ្ជកម្មជកសេវាកម្មនិងដកប្រាក់បង្វែរផ្នែកឯកជន

**រូបលេខ 12** កំណើនប្រាក់បញ្ញើទាប ប៉ុន្តែឥណទាននៅតែមានកំណើនខ្ពស់



ប្រភព: ធនាគារជាតិនៃកម្ពុជា

ការណ៍នេះបង្កើនហានិភ័យនៃការមានបញ្ហាសាច់ប្រាក់ងាយស្រួលនៅក្នុងប្រព័ន្ធធនាគារ។ អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើបន្តកើនឡើង កើនពី 80 ភាគរយ នៅចុងឆ្នាំ 2012 ដល់ 90 ភាគរយ នៅចុងឆ្នាំ 2013។ ទោះជាយ៉ាងណាក្តី កម្រិតនេះនៅតែទាបជាងកម្រិតខ្ពស់បំផុតស្មើនឹង 100 ភាគរយ កាលពីមុនពេលមានវិបត្តិខណៈពេលដែលវិស័យសំណង់ និងអចលនទ្រព្យកំពុងមានសន្ទុះខ្លាំងក្លា (រូបលេខ 13)។

**រូបលេខ 13** អនុបាតរវាងឥណទាននិងប្រាក់បញ្ញើកំពុងកើនឡើង ប៉ុន្តែកំណើននេះមានកម្រិតទាបជាងមុនពេលមានវិបត្តិ



ប្រភព: ធនាគារជាតិនៃកម្ពុជា

កំណើនរូបិយវត្ថុទូទៅក៏បានធ្លាក់ចុះ ព្រោះថាប្រាក់បញ្ញើរូបិយប័ណ្ណបរទេស មានការកើនឡើងយឺតដល់ 6,7 ពាន់លានដុល្លារអាមេរិក ឬ 14,6 ភាគរយ ក្នុងឆ្នាំ 2013 ធៀបនឹង 5,9 ពាន់លានដុល្លារអាមេរិក ឬ 20,9 ភាគរយ ក្នុងឆ្នាំ 2012 (រូបលេខ 14)។

**រូបលេខ 14** រូបិយវត្ថុទូទៅធ្លាក់ចុះនៅពេលដែលកំណើនប្រាក់បញ្ញើបរទេសមានកម្រិតទាប



ប្រភព: ធនាគារជាតិនៃកម្ពុជា

ទុនបម្រុងអន្តរជាតិដុល បានកើនឡើងតិចតួចពី 3,5 ពាន់លានដុល្លារអាមេរិក ឬស្មើនឹងការនាំចូលរយៈពេល 3,1 ខែ នៅចុងឆ្នាំ 2012 ដល់ 3,6 ពាន់លានដុល្លារអាមេរិក ឬ ស្មើនឹងការនាំចូលរយៈពេល 3,8 ខែនៅចុងឆ្នាំ2013 (រូបលេខ 15 និង លេខ 16)។

**រូបលេខ 15** ទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគាជាតិនៃកម្ពុជាកើនឡើង ប៉ុន្តែទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារដែលទទួលប្រាក់បញ្ញើធ្លាក់ចុះនៅឆ្នាំ 2013 ដោយសារកំណើនខ្ពស់នៃឥណទាន គិតជាលានដុល្លារ



សំគាល់: DMB: ធនាគារទទួលប្រាក់បញ្ញើ
ប្រភព: ធនាគារជាតិនៃកម្ពុជា

គិតជាភាគរយនៃប្រាក់បញ្ញើក្នុងវិស័យឯកជន ទុនបម្រុងអន្តរជាតិដុលបាននឹងកំពុងថយចុះពី 57 ភាគរយ នៅចុងឆ្នាំ 2012 នេះមកត្រឹម 53 ភាគរយ នៅចុងឆ្នាំ 2013 (រូបលេខ 16)។

**រូបលេខ 16** ទុនបំរុងអន្តរជាតិដុល (GIR) បង្ហារសម្រាប់ការធ្លាក់ចុះនៃប្រាក់បញ្ញើពីវិស័យឯកជន




ប្រភព:ធនាគារជាតិនៃកម្ពុជានិងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

ធនាគារកណ្តាល មានមុខងារជាអ្នកផ្តល់ប្រាក់កម្ចីចុងក្រោយ កំពុងជួបឧបសគ្គកាន់តែខ្លាំងដោយសារដុល្លារូបនីយកម្មយ៉ាងខ្ពស់ នៃសេដ្ឋកិច្ច។ ចំណែកនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស នៅក្នុងរូបិយវត្ថុទូទៅបានកើនពី 71 ភាគរយនៅចុង-2005 ដល់ 82 ភាគរយនៅចុងឆ្នាំ 2013 (រូបភាពទី 17) ។

**រូបលេខ 17** **ចំណែកប្រាក់បញ្ញើជារូបិប័ណ្ណបរទេសនៅក្នុងរូបិយវត្ថុទូទៅកើនឡើងពី 71 ភាគរយនៅឆ្នាំ2005 ដល់ 82 ភាគរយនៅឆ្នាំ 2013 មានន័យថា ដុល្លារូបនិយកម្មកើនឡើង**




ប្រភព:ធនាគារជាតិនៃកម្ពុជា

### *តើគោលនយោបាយនិងផែនការនាំចេញអង្ករឈានអាចអនុវត្តដោយជោគជ័យដែរឬទេ?*

មុនឆ្នាំ 2010 កម្ពុជាបាននាំចេញអង្ករត្រឹមតែពីរបីពាន់តោនប៉ុណ្ណោះ។ ឯកសារគោលនយោបាយស្រូវអង្ករដែលបានបានអនុម័តក្នុងខែកក្កដាឆ្នាំ 2010 បានជំរុញការផលិតនិងការនាំចេញអង្ករជាមួយនឹងផែនការ យ៉ាងហោចណាស់ 1 លានតោនក្នុងមួយឆ្នាំ 2015។

គោលនយោបាយនេះជួយកៀរគរធនធាន និងបច្ចេកវិទ្យាទៅកាន់ក្នុងម៉ាស៊ីនកិនស្រូវនិងផលិតកម្មអង្ករ។វិស័យ ឯកជនជម្រុញដឹកនាំ ការនាំចេញអង្ករ ខណ:ពេលដែលវិស័យសាធារណ:សម្របសម្រួលពាណិជ្ជកម្មតាមរយ:ការបង្កើតមធ្យោបាយសេវាច្រកចេញចូលតែមួយ ធានាដល់ទីផ្សារនាំចេញ និងផ្តល់ប្រាក់កម្ចីមួយចំនួន។ នៅឆ្នាំ 2013 ធនាគារបានផ្តល់ឥណទាន 700 លានដុល្លារ អាមេរិក ឬ 11 ភាគរយនៃឥណទានសរុបដល់វិស័យកសិកម្ម ធៀបនឹងបរិមាណឥណទានជាង 100 លានដុល្លារអាមេរិកដែល វិស័យនេះទទួលបាននៅឆ្នាំ 2008 ។ កិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយនិងបង្កើនការយល់ដឹងបានផ្តល់ផ្លែផ្កាហើយកម្ពុជា បានទទួលពានរង្វាន់អង្ករក្រអូបល្អបំផុតរបស់ពិភពលោកជាបន្តបន្ទាប់ក្នុងឆ្នាំ 2012 និង 2013 ។ ការនាំចេញអង្ករនៅឆ្នាំ 2013 បានកើនឡើងដល់ 380 ពាន់តោន ឬស្ទើរតែមានចំនួនពីរដងជាច្រើនធៀបនឹងឆ្នាំ 2012។

ខណ:ពេលដែលគេត្រូវរង់ចាំមើលឃើញថាតើផែនការនាំចេញអង្ករនឹងត្រូវបានសម្រេចក្នុងឆ្នាំ 2015 ឬយ៉ាងណានោះ ជោគជ័យក្នុងការកៀរគរធនធាននិងបច្ចេកវិទ្យាធ្វើឲ្យទទួលបានសមិទ្ធិផលថ្មីៗនេះ ជាការផ្តល់កម្លាំងចិត្ត។




ប្រភព: អគ្គនាយកដ្ឋានគយនិងរដ្ឋាករ

**គោលនយោបាយកំណត់អត្រាប្តូរប្រាក់រួមចំណែកធ្វើអោយអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានស្ថិរភាព។** អត្រាប្តូរប្រាក់មិនប្រែប្រួលក្នុងអត្រា 3.995រៀល ក្នុងមួយដុល្លារអាមេរិកនៅចុងឆ្នាំ2013 អត្រាប្តូរប្រាក់ដូចគ្នានេះត្រូវបានកត់

គ្រានៅចុងឆ្នាំ 2012។ ធនាគារកណ្តាល (ធនាគារជាតិនៃកម្ពុជា)បន្តកំណត់អត្រាប្តូរប្រាក់។ ប្រាក់រៀលនៅតែបន្តកំណត់ភ្ជាប់នឹងប្រាក់ដុល្លារអាមេរិក ហើយជាទូទៅ អត្រាប្តូរប្រាក់មានស្ថិរភាពជុំវិញ 4.000 រៀល ក្នុងមួយដុល្លារ។ ខណៈដែលប្រាក់ដុល្លារ អាមេរិកឡើងថ្លៃ ប្រាក់រៀលក៏ឡើងថ្លៃធៀបនឹងប្រាក់ដុងវៀតណាម ហើយក៏បានចាប់ផ្តើមឡើងថ្លៃធៀប នឹងប្រាក់បាតថៃចាប់តាំងពីពាក់កណ្តាល ឆ្នាំ 2013មក(រូបលេខ 18) ។

រូបលេខ 18 ប្រាក់រៀលឡើងថ្លៃធៀបនឹងប្រាក់ដុងហើយកាលពីថ្មីៗនេះក៏ឡើងថ្លៃធៀបនឹងប្រាក់ បាតផងដែរ




ប្រភព:ធនាគារកណ្តាល(កម្ពុជា និងថៃ)និងក្រសួងហិរញ្ញវត្ថុវៀតណាម

ហេតុនេះដោយសារតែការភ្ជាប់ទៅនឹងប្រាក់ដុល្លារអាមេរិកបែបនេះ ការឡើងថ្លៃជាធម្មតានៃប្រាក់រៀលរបស់កម្ពុជា ធៀបនឹងរូបិយប័ណ្ណក្នុងតំបន់ទំនងជាកើតមានបន្តទៀត។ ទោះជាយ៉ាងណាក្តី អត្រាប្តូរប្រាក់ពិតនៃប្រាក់រៀល បន្តធ្លាក់ថ្លៃ (រូបលេខ 19) ដោយសារប្រាក់ដុល្លារអាមេរិកបាននឹងកំពុងធ្លាក់ថ្លៃ ធៀបនឹងរូបិយប័ណ្ណសំខាន់ៗផ្សេងទៀត ដូចជា អឺរ៉ូ និងប្រាក់យាន់របស់ចិន ដែលជាដៃគូពាណិជ្ជកម្មដ៏សំខាន់របស់ប្រទេសកម្ពុជាផងដែរ[9]។

រូបលេខ 19 អត្រាប្តូរប្រាក់ពិត (REER) បន្តធ្លាក់ថ្លៃ




សំគាល់: NEER = អត្រាប្តូរប្រាក់ជាក់ស្តែង

ប្រភព:IFS

ធនាគារកណ្តាល បន្តពង្រឹងស្ថិរភាពនៃវិស័យធនាគារ និងវិស័យហិរញ្ញវត្ថុ ក៏ដូចជាពង្រឹងសមត្ថភាពគ្រប់គ្រង និងការត្រួតពិនិត្យរបស់ខ្លួន។ ថ្មីៗនេះ គំនិតល្អៗ ត្រូវបានផ្តួចផ្តើមដើម្បីពិនិត្យមើលឡើងវិញ នូវក្របខណ្ឌគតិយុត្តិសម្រាប់ធនាគារ និងវិស័យហិរញ្ញវត្ថុ។

### *បរិយាកាសសេដ្ឋកិច្ចពិភពលោក និងផលប៉ះពាល់របស់វា*

កំណើននៅបណ្តាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ត្រូវបានព្យាករថានឹងកើនឡើងពី 1,3 ភាគរយ នៅឆ្នាំ 2013 ដល់ 2,2 ភាគរយ នៅឆ្នាំនេះ និង 2,4 ភាគរយ នៅឆ្នាំ 2015 និងឆ្នាំ 2016 ។ សេដ្ឋកិច្ចសហរដ្ឋអាមេរិក ត្រូវបានគេព្យាករថានឹងកើនឡើងពី 1,8 ភាគរយ នៅក្នុងឆ្នាំ 2013 ដល់ 2,8 ភាគរយនៅឆ្នាំនេះ។ កំណើនសេដ្ឋកិច្ចនៅតំបន់អឺរ៉ុប បន្ទាប់ពីការធ្លាក់ចុះអស់រយៈពេលពីរឆ្នាំ ត្រូវបានគេរំពឹងថាមានអត្រាស្មើនឹង 1,1 ភាគរយ នៅឆ្នាំនេះ។ នៅពេលដែលសេដ្ឋកិច្ចអាមេរិកមានភាពប្រសើរឡើង ធនាគារសហព័ន្ធអាមេរិកបាន

[9] អត្រាប្តូរប្រាក់ពិតគឺជាតម្លៃមធ្យម ដែលត្រូវបានកែតម្រូវអតិផរណាទៅតាមមេគុណ (មេគុណនេះត្រូវបានប្រទេសកម្ពុជាកំណត់សារៈសំខាន់លើរូបិយប័ណ្ណដទៃទៀតដែលបានជួញដូរ)នៃរូបិយវត្ថុក្នុងស្រុកធៀបនឹងរូបិយប័ណ្ណសំខាន់ៗដែលកំពុងជួញដូរ។ សន្ទស្សន៍អត្រាប្តូរប្រាក់ពិតបានកើនដល់ 131(2005=100)នៅឆ្នាំ 2013 ឬកើនឡើង 1.8 ភាគរយធៀបនឹងឆ្នាំមុន សឲ្យឃើញការធ្លាក់ថ្លៃនៃអត្រាប្តូរប្រាក់ពិតរបស់កម្ពុជា។

សម្រេចចិត្តកាត់បន្ថយបន្តិចម្តងៗ នូវល្បឿននៃកម្មវិធីទិញមូលប័ត្ររបស់ខ្លួន[10]។ ខណៈពេលដែលការបង្កើនតម្រូវការនៅក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់ នឹងពង្រីកពាណិជ្ជកម្មពិភពលោក ទ្រទ្រង់ដោយកំណើននាំចេញពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជាជាដើម ប៉ុន្តែការធ្វើឲ្យអត្រាការប្រាក់រយៈពេលវែងមានសភាពធម្មតា ត្រូវបានគេរំពឹងថា នឹងប៉ះពាល់ដល់លំហូរមូលធនទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍[11]។

បណ្តាប្រទេសដែលមានប្រាក់ចំណូលទាបដូចប្រទេសកម្ពុជា ដែលធ្វើសមាហរណកម្មតិចតួចទៅក្នុងទីផ្សារហិរញ្ញវត្ថុពិភពលោក អាចនឹងរងផលប៉ះពាល់ តាមរយៈការរឹតបន្តឹងស្ថានភាពហិរញ្ញវត្ថុពិភពលោក ពិសេសតាមរយៈបណ្តាញពាណិជ្ជកម្ម។ ការធ្លាក់ថ្លៃនៃរូបិយប័ណ្ណក្នុងស្រុកដែលប្រទេសកំពុងអភិវឌ្ឍន៍ ភាគច្រើននឹងជួបប្រទះ ជាទូទៅនឹងធ្វើឲ្យការនាំចេញរបស់ពួកគេមានភាពប្រកួតប្រជែងកាន់តែខ្ពស់ (រូបលេខ 20)។ ទោះជាយ៉ាងណាក្តី សភាពការណ៍នេះមានលក្ខណៈផ្ទុយគ្នា ក្នុងករណីនៃការនាំចេញរបស់កម្ពុជា ដោយសារតែសេដ្ឋកិច្ចកម្ពុជាចរាចរប្រាក់ដុល្លារយ៉ាងខ្ពស់។

រូបលេខ 20 ការធ្លាក់ថ្លៃអត្រាប្តូរប្រាក់របស់គូប្រជែងនៃកម្ពុជាក្នុងការនាំចេញសម្លៀកបំពាក់

រូបិយវត្ថុក្នុងស្រុកធៀបនឹងប្រាក់ដុល្លារខែមករា ឆ្នាំ 2000 = 100




ប្រភព: ធនាគារកណ្តាល និង x-rates.com

បន្ថែមពីលើនេះ មានហានិភ័យអំពីការកាត់បន្ថយការវិនិយោគក្នុងប្រទេសចិន ការធ្លាក់ចុះកំណើនផលិតផលក្នុងស្រុកសរុបរបស់ចិន ដែលអាចបណ្តាលឲ្យមានឥទ្ធិពលផ្សេងទៀតនៅក្នុងតំបន់ និង ប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ប្រទេសផ្សេងទៀតដែលមានទំនាក់ទំនងពាណិជ្ជកម្មជិតស្និទ្ធ[12]។ ខណៈពេលដែលដៃគូនាំចេញចម្បងរបស់កម្ពុជា គឺសហភាពអឺរ៉ុបនិងសហរដ្ឋអាមេរិក ប្រទេសចិនស្ថិតក្នុងចំណោមប្រភពធំបំផុតនៃវិនិយោគផ្ទាល់ពីបរទេសនៅប្រទេសកម្ពុជា(រូបទី21)[13] ។

[10] ធនាគារសហព័ន្ធបានបន្ថែមមូលបត្រទីភ្នាក់ងារដែលសំអាងដោយនិក្ខេបក្នុងការកាន់កាប់របស់ខ្លួន ក្នុងកម្រិតត្រឹមតែ 30 ពាន់លានដុល្លារប៉ុណ្ណោះ ក្នុងខែកុម្ភៈធៀប 35 ពាន់លានដុល្លារអាមេរិក ក្នុងខែមករាឆ្នាំ 2014 និង 40 ពាន់លានដុល្លារអាមេរិកក្នុងមួយខែកាលពីឆ្នាំមុន ហើយក៏បានបន្ថែមមូលបត្ររតនាគាររយៈពេលវែងចំនួន 35 ពាន់លានដុល្លារសហរដ្ឋអាមេរិកក្នុងខែកុម្ភៈធៀបនឹង 40 ពាន់លានដុល្លារនៅខែមករាឆ្នាំ 2014 និង 45 ពាន់លានដុល្លារអាមេរិកក្នុងមួយខែកាលពីឆ្នាំមុន។ សម្រាប់ព័ត៌មានលម្អិតសូមមើលការចេញផ្សាយសារព័ត៌មានរបស់ FOMC: មករា 29, 2014 និងខែធ្នូ 18, 2013 ។

[11] តាមទស្សនៈអនាគតស្តីពីការអភិវឌ្ឍ របស់ធនាគារពិភពលោក

[12] ការនាំចេញអង្កររបស់កម្ពុជាទៅកាន់ប្រទេសចិនមានកំណើនយឺត។ នៅឆ្នាំ 2013 ប្រទេសកម្ពុជាបាននាំចេញអង្ករតែប្រមាណជា 28.000 តោន(ឬ 7,5 ភាគរយនៃការនាំចេញអង្ករសរុប) ប៉ុណ្ណោះទៅកាន់ប្រទេសចិន។

[13] ទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (វិនិយោគលើអចលនទ្រព្យ( ដែលអាចប្រើជាទិន្នន័យជំនួសការវិនិយោគផ្ទាល់ពីបរទេសបង្ហាញថា ការវិនិយោគផ្ទាល់របស់ប្រទេសចិនគ្របដណ្តប់យ៉ាងហោចណាស់ 10 ភាគរយនៃការវិនិយោគសរុបនៅប្រទេសកម្ពុជា

រូបលេខ 21 ចិននៅតែជាប្រទេសវិនិយោគច្រើនជាងគេ ប៉ុន្តែចំណែកភាគរយកំពុងធ្លាក់ចុះ

គំរោងវិនិយោគលើទ្រព្យសកម្មអចល័តពីប្រទេសចិនដែលបានឯកភាព(ពាន់លានដុល្លារអាមេរិក)




ប្រភព:កអក

**តម្លៃប្រេងពិភពលោកនិងតម្លៃស្រូវកំពុងតែទន់ខ្សោយ។** តម្លៃប្រេងពិភពលោកបានបន្តធ្លាក់ចុះក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ។ តម្លៃប្រេងនៅជាមធ្យម 104,៨ដុល្លារ/ធុងនៅខែកុម្ភៈ 2014 0,6ភាគរយទាបជាងខែធ្នូ និង 2,6ភាគរយទាបជាងមួយឆ្នាំកន្លងទៅ។[14] ប្រេងមធ្យមជាក់ស្តែងត្រូវបានរំពឹងថាស្មើនឹង 103,5 ដុល្លារ/ធុង ក្នុងឆ្នាំនេះ( ចុះពី104 ដុល្លារ/ធុង ក្នុងឆ្នាំ 2013) និងធ្លាក់ចុះដល់ 100 ដុល្លារ/ធុង នៅឆ្នាំ 2015 ដោយសារការបង្កើនការផលិតប្រេងខុស ពីមធ្យោបាយសព្វមួយដង ខណៈពេលដែលតម្រូវការកំពុងកើនឡើងដែរនោះ[15]។ ការផ្គត់ផ្គង់ដ៏ច្រើនលើសលប់ជាមួយនឹងការបញ្ចេញអង្ករដោយប្រទេសថៃបានធ្វើឲ្យធ្លាក់ចុះនូវតម្លៃអង្ករនៅលើទីផ្សារ។ តម្លៃអង្ករបានចុះដល់កម្រិតទាបបំផុតក្នុងរយៈ 3,5 ឆ្នាំកាលពីខែធ្នូឆ្នាំ 2013 ។ តម្លៃអង្ករជាមធ្យម 459 ដុល្លារ/តោន ក្នុងខែកុម្ភៈ ខ្ពស់ជាងខែធ្នូ 1,8 ភាគរយ ប៉ុន្តែទាបជាងមួយឆ្នាំមុន 18 ភាគរយ ហើយពាក់កណ្តាលបើធៀបទៅនឹងដើមឆ្នាំ 2008 ដែលអង្ករមានតម្លៃខ្ពស់គ្រប់ពេល។ តម្លៃអង្ករត្រូវរំពឹងថាមាន តម្លៃ460ដុល្លារ/តោនឆ្នាំនេះ (ចុះពី 505,9ដុល្លារ/តោន ក្នុងឆ្នាំ2013) នឹងចុះដល់ 450ដុល្លារ/តោន ក្នុងឆ្នាំ2015។ សម្រាប់ប្រទេសកម្ពុជាការធ្លាក់ចុះតម្លៃប្រេង ផ្តល់អត្ថប្រយោជន៍ដោយសារកម្ពុជានាំចូលផលិតផលប្រេង 100 ភាគរយ សម្រាប់ប្រើប្រាស់។ ទោះជាយ៉ាងណាក្តី ការធ្លាក់ចុះតម្លៃអង្ករ ទំនងជាប៉ះពាល់ដល់សេដ្ឋកិច្ច ដោយសារប្រទេសកម្ពុជាជាប្រទេសនាំចេញអង្ករច្រើនជាងការនាំចូល។

14 សង្ខេបសេដ្ឋកិច្ចប្រចាំសប្តាហ៍ ក្រុមអភិវឌ្ឍន៍ទស្សនៈវិស័យធនាគារពិភពលោក 7 មិនា 2014

15 តាមការព្យាករតម្លៃទំនិញរបស់ធនាគារពិភពលោក ខែមករា2014

## សំហាសារពើពន្ធ

**ខណៈពេលដែលស្ថានភាពសារពើពន្ធនៅតែស្ថិតនៅក្រោមការគ្រប់គ្រង ចំណូលក្នុងស្រុករបស់រដ្ឋាភិបាលមានកំណើនទាប** ។ បន្ទាប់ពីការកើនឡើងយ៉ាងខ្លាំងនៅឆ្នាំ 2012 កំណើនចំណូលក្នុងស្រុកមានកម្រិតទាប ត្រូវបានប៉ាន់ស្មានថាកើនឡើងប្រមាណជា 5.0ភាគរយប៉ុណ្ណោះ នៅឆ្នាំ 2013 ធៀបនឹង 30,6 ភាគរយ នៅឆ្នាំ 2012 ។ សភាពការណ៍នេះមួយផ្នែកធំ បណ្តាលមកពីល្បឿននៃការប្រមូលពន្ធនាំចូលយឺត និងល្បឿននៃការប្រមូលចំណូលមិនមែនពន្ធ និងចំណូលខេត្តយឺត ។ ចំណូលពន្ធនាំចូលមិនបានកើនឡើងច្រើនដូចបានរំពឹងទុកឡើយ ដោយសារកំណើនបរិមាណនាំចូលកើនឡើងទាប ទោះបីជាអាជ្ញាធរគយប្រឹងប្រែងប្រមូលពន្ធគយជាផ្លូវការក្តី។ ចំណូលឆ្នាំ 2013 ត្រូវបានប៉ាន់ស្មានថា នឹងកើនឡើងដល់ 14,8ភាគរយនៃផសសទាបជាងឆ្នាំ2012ដែលកើនខ្ពស់បំផុតស្មើនឹង 15,3ភាគរយ(រូបលេខ 22)។ ទោះជាយ៉ាងណាក្តី អាជ្ញាធរទទួលជោគជ័យ ក្នុងការលើកកម្ពស់ការគ្រប់គ្រង និងការប្រមូលចំណូលមិនមែនពន្ធ។ ការដាក់ឲ្យអនុវត្តប្រព័ន្ធទទួលចំណូលមិនមែនពន្ធ ដែលមានលក្ខណៈស្តង់ដារ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់នៅក្នុងឆ្នាំ 2012 និងប្រកាសអន្តរក្រសួងត្រូវបានអនុវត្តក្នុង

ឆ្នាំ2013 ក្នុងការធ្វើវិចារណកម្ម និងសុខុដុមនីយកម្មថ្លៃ និងអត្រាសេវាចំពោះ ភ្នាក់ងារប្រមូលចំណូលមិនមែនពន្ធនានា បានធ្វើឲ្យមានសន្ទុះដល់ការប្រមូលចំណូលមិនមែនពន្ធ[16]។ ការងារនេះបានទទួលការគាំទ្រដោយ ធនាគារពិភពលោកក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល[17]។

**រូបលេខ 22** **កំណើនចំណូលក្នុងស្រុកទាបធ្វើឲ្យអនុបាតចំណូលធៀបនឹង ផសស ឆ្នាំ 2013 និង 2014 ធ្លាក់ចុះ**

សមាសភាគចំណូលគិតជាភាគរយនៃ ផសស




សំគាល់: e = ប៉ាន់ស្មាន b = ថវិកា

ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ទោះជាយ៉ាងណាក្តី ចំណាយត្រូវបានប៉ាន់ស្មានថាកើនឡើងលឿនជាង គឺកើនឡើង 9,8 ភាគរយនៅឆ្នាំ 2013 ធៀប នឹងការកើនឡើង 3,1 ភាគរយនៅ ឆ្នាំ 2012 និងត្រូវបានគេប៉ាន់ស្មានថានឹងកើនឡើងដល់ប្រមាណជា 21,3ភាគរយ នៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ2013 ខ្ពស់ជាងឆ្នាំ2012 បន្តិច (រូបភាពទី 23) ។

**រូបលេខ 23** **មានកិច្ចប្រឹងប្រែងកាត់បន្ថយចំណាយសរុបរបស់រដ្ឋាភិបាល**

សមាសភាគចំណាយសំខាន់ៗគិតជាភាគរយនៃ ផសស




ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

ឱនភាពថវិកាទូទៅឆ្នាំ2013 ដែលរួមមានជំនួយឥតសំណងត្រូវបានប៉ាន់ស្មានថា នឹងកើនឡើងដល់ 3,9 ភាគរយនៃផសស ខ្ពស់ជាងឱនភាពឆ្នាំ 2012 ចំនួន 3.3 ភាគរយ (រូបលេខ 24) ។ លើសពីនេះទៀត ការផ្តល់ហិរញ្ញប្បទានលើសលប់ពីបរទេសនឹងនៅបន្តទៅទៀត។

**រូបលេខ 24** **កំណើនតិចតួចនៃឱនភាពសារពើពន្ធសរុបបន្តទទួលហិរញ្ញប្បទានយ៉ាងច្រើនពីមូលនិធិក្រៅប្រទេស**

ភាគរយនៃ ផសស




ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

ជាលទ្ធផល ប្រាក់សន្សំរបស់រដ្ឋាភិបាលបានកើនពី 2.486 រៀលពាន់លានដុល្លារ (ឬប្រហែល 690 លានដុល្លារសហរដ្ឋអាមេរិក) ក្នុងឆ្នាំ 2012 ដល់ 2,750 ពាន់លានរៀល (ឬប្រហែល 760 លានដុល្លារអាមេរិក) នៅឆ្នាំ 2013 (រូបភាពទី 25)[18] ។

---

16 មានការប៉ាន់ប្រមាណថាវិធានការនេះបានបន្ថែមប្រហែល 25 លានដុល្លារអាមេរិកលើសដែនការចំណូលមិនមែនពន្ធក្នុងថវិកាឆ្នាំ 2012 ។ ចំណូលមិនមែនពន្ធបានកើនឡើងដល់ 2,5 ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ 2012 ពី 2.0 ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ 2011

17 ក្រោម PFMRPអនុបាតចំណូលធៀបនឹងផសសត្រូវបានគ្រោងថានឹងកើនឡើង 0.5 ភាគរយ ក្នុងមួយឆ្នាំ។

18 ប្រាក់សន្សំរបស់រដ្ឋាភិបាលឬឥណទានសុទ្ធ(អវិជ្ជមាន) ផ្តល់ឱ្យរដ្ឋាភិបាលដោយប្រព័ន្ធធនាគារ គឺជាប្រាក់សន្សំដែលទទួលបានពីអតិរេកដែលរដ្ឋាភិបាលបានប្រមូលផ្តុំដោយសារការផ្តល់ហិរញ្ញ

គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប ប្រាក់សន្សំរបស់រដ្ឋាភិបាលបានកើនឡើងតិចតួចពី 4,8 ភាគរយនៅក្នុងឆ្នាំ 2012 ដល់ 4,9 ភាគរយនៅឆ្នាំ 2013 ។

រូបលេខ 25 ការកើនឡើងនៃប្រាក់សន្សំរបស់រដ្ឋាភិបាល

ប្រាក់បញ្ញើរដ្ឋាភិបាលសរុបគិតជាពាន់លានរៀល




ប្រភព: ធនាគារជាតិនៃកម្ពុជា

ចាប់តាំងពីឆ្នាំ 2012 មក ការពង្រឹងផ្នែកសារពើពន្ធដែលគាំទ្រ ដោយការកើនឡើងគួរឲ្យសម្គាល់នូវការប្រមូលចំណូលក្នុងស្រុក បានអនុញ្ញាតឱ្យអាជ្ញាធរកសាងលំហសារពើពន្ធសាជាថ្មី[19]។ ជាមួយ នឹងសេដ្ឋកិច្ចដែលប្រើប្រាស់ប្រាក់ដុល្លារអាមេរិកជាទូទៅ គោលនយោបាយសារពើពន្ធជាឧបករណ៍គោលនយោបាយដ៏សំខាន់ សម្រាប់គ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ចំណែកឯ លំហសារពើពន្ធដែលបានបង្កើតឡើង ដោយកំណើននៃការប្រមូលចំណូលក្នុងស្រុក គឺជាការចាំបាច់ក្នុងការបំពេញតួនាទីជាទ្រនាប់ទប់ទល់នឹងវិបត្តិនានាក្នុងពេលអនាគត។ ទោះជាយ៉ាងណាក្តីការកសាងលំហសារពើពន្ធ នឹងកាន់តែមានការលំបាកខ្លាំងឡើង ដោយសារតម្រូវការប្រកួតប្រជែងក្នុងការចំណាយ រាប់ទាំងសម្ពាធពីកំណើនបញ្ជីបៀវត្សនៃវិស័យសាធារណៈផងដែរ។ នៅក្នុងថវិកាឆ្នាំ 2014 បញ្ជីបៀវត្សនៃវិស័យសាធារណៈត្រូវបានកំណត់បង្កើនពី 40 ភាគរយ ទៅ 45 ភាគរយ នៃការចំណាយចរន្តសរុប។ បញ្ជីបៀវត្សសរុបនៅក្នុងឆ្នាំ 2014 មានទំហំទឹកប្រាក់ជាង 5 ភាគរយ នៃផលិតផលក្នុងស្រុកសរុប។ វិភាជន៍ថវិកាតាមវិស័យ ពិសេសសម្រាប់វិស័យអប់រំក៏បានទទួលសន្ទុះកំណើនយ៉ាងច្រើនពីវិភាជន៍ថវិកា ក្នុងឆ្នាំ 2014 ស្របជាមួយនឹងអនុសាសន៍ដែលបានផ្តល់នៅក្នុងការពិនិត្យឡើងវិញចំណាយសាធារណៈ ឆ្នាំ 2011[20] ។

## *និរន្តរភាពបំណុល*

**ចំណាត់ថ្នាក់ភាពតានតឹងផ្នែកបំណុលនៃប្រទេសកម្ពុជានៅមានកម្រិតទាបនៅឡើយ។** ការវិភាគរួមគ្នារវាងធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តជាតិអំពីនិរន្តរភាពបំណុល (DSA) ក្នុងឆ្នាំ 2013 បានបង្ហាញថាចំណាត់ថ្នាក់ភាពតានតឹងផ្នែកបំណុលនៃប្រទេសកម្ពុជានៅមានកម្រិតទាប ខណៈដែលសូចនាករបន្ទុកបំណុលទាំងអស់ត្រូវបានព្យាករថាស្ថិតក្រោមកម្រិតគោលនៃសូចនាករបន្ទុកបំណុលទាំងនោះ។ ប្រការនេះដោយសាររដ្ឋាភិបាលមានគោលនយោបាយចៀសវាងការខ្ចីប្រាក់គ្មានសម្បទាន។ ស្រដៀងគ្នាទៅនឹងការវាយតម្លៃកាលពីឆ្នាំ 2012 ដែរ លទ្ធផលបង្ហាញថា

ប្បទានលើសចំណាយទូទៅនៃថវិកាប្រចាំឆ្នាំ។ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំសារពើពន្ធរបស់រដ្ឋាភិបាល ប្រាក់សន្សំប្រចាំឆ្នាំរបស់រដ្ឋាភិបាលគឺជាហិរញ្ញប្បទានអវិជ្ជមានក្នុងស្រុក។

[19] យោងតាមព្រឹត្តិប័ត្រហិរញ្ញវត្ថុនិងការអភិវឌ្ឍ, លេខ 2, ភាគ 42, ខែមិថុនាឆ្នាំ 2005 របស់ IMF "លំហសារពើពន្ធ" គឺជា ចំណែកថវិកាមួយផ្នែករបស់រដ្ឋាភិបាលដែលអាចប្រើប្រាស់ជាធនធានក្នុងការសម្រេចគោលបំណងណាមួយដោយមិនធ្វើឱ្យប៉ះពាល់ដល់និរន្តរភាពនៃស្ថានភាពហិរញ្ញវត្ថុ ឬស្ថិរភាពនៃការសេដ្ឋកិច្ចរបស់ខ្លួន

[20] នេះជាផ្នែកមួយនៃការវាយតម្លៃចំរុះលើទំនុកចិត្តនិងការពិនិត្យសើរើឡើងវិញលើចំណាយសាធារណៈ(IFAPER) ធនាគារពិភពលោក ឆ្នាំ 2011។

និរន្តរភាពបំណុលនៅតែងាយរងគ្រោះចំពោះកំណើនសេដ្ឋកិច្ច ការនាំចេញ និងវិបត្តិសារពើពន្ធ។ ប្រការនេះតម្រូវឲ្យមានការធ្វើកំណែទម្រង់រចនាសម្ព័ន្ធជាបន្តដើម្បីធ្វើពិពិធកម្មកំណើន និងកែលម្អការប្រមូលចំណូល ក៏ដូចជាគ្រប់គ្រងបំណុលយថាភាព។ ទំហំបំណុលបរទេសរបស់ប្រទេសកម្ពុជា (រួមទាំងបំណុលកកស្ទះ) មានចំនួន 4,5 ពាន់លានដុល្លារអាមេរិក ឬ 32 ភាគរយនៃផសស នៅចុងឆ្នាំ 2012 ហើយត្រូវបានព្យាករណ៍ថានឹងកើនដល់ 5,1 ពាន់លានដុល្លារអាមេរិក ឬ 32.8 ភាគរយ នៃផសស នៅចុងឆ្នាំ 2013។

# សារគន្លឹះ

ការគ្រប់គ្រងសម្ពាធក្នុងស្រុកឱ្យបានត្រឹមត្រូវដើម្បីទទួលផលពី បរិយាកាសសេដ្ឋកិច្ចពិភពលោកប្រសើរឡើង ជាមួយនឹងការត្រៀមខ្លួនដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមាន ដែលអាចកើតមានពីការកាត់បន្ថយ ការអនុវត្តគោលនយោបាយជំរុញសេដ្ឋកិច្ចនៃធនាគារសហព័ន្ធអាមេរិក និងការធ្លាក់ចុះសេដ្ឋកិច្ចរបស់ប្រទេសចិន នឹងជួយការពារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ការណ៍នេះតម្រូវឱ្យដោះស្រាយបានគ្រប់គ្រាន់ ចំពោះហានិភ័យដែលអាចខាតបង់ដូចបានពិភាក្សាខាងលើដើម្បីឲ្យកត្តាជំរុញកំណើនត្រូវបានពង្រឹងបន្ថែមទៀត។

ខាងផ្នែករចនាសម្ព័ន្ធ គប្បីធ្វើឱ្យប្រសើរឡើងនូវការបណ្តុះបណ្តាលនិងការអប់រំការងារ សម្រាប់កម្មករនិងសិស្ស ដើម្បីបង្កើនផលិតភាពពលកម្ម និងជាថ្នូរនៃកំណើនប្រាក់ឈ្នួល និងដើម្បីបន្តទាក់ទាញកម្លាំងពលកម្មពីតំបន់ជនបទ ទៅក្នុងវិស័យកម្មន្តសាល។ ការដោះស្រាយភាពចលាចលផ្នែកការងារតាមរយៈការចរចា ដោយជោគជ័យលើបញ្ហាប្រាក់ឈ្នួល និងបម្រើផលប្រយោជន៍ទាំងកម្មករនិងក្រុមហ៊ុន។ ទន្ទឹមនឹងនេះដែរ ការលើកកំពស់សមាហរណកម្ម ក្នុងតំបន់តាមរយៈការធ្វើកំណែទម្រង់រចនាសម្ព័ន្ធស៊ីជម្រៅ តាមរយៈកិច្ចសម្រួលពាណិជ្ជកម្មទាក់ទងនឹងការរត់ការឯកសារនាំចូលនិងនាំចេញជាមួយនឹងនិតិវិធីសាមញ្ញ និងស៊ីសង្វាក់គ្នាជាមួយនីតិវិធី ទំនាក់ទំនងរវាងហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូនសម្រាប់ការតភ្ជាប់បណ្តាញក្នុងតំបន់ និងសេវាកម្មផ្គត់ផ្គង់ នឹងបង្កលក្ខណៈឱ្យប្រទេសកម្ពុជាទទួលបានអត្ថប្រយោជន៍កាន់តែច្រើនពីសក្តានុពលកំណើននៅទូទាំងតំបន់អាស៊ាន។ ការណ៍នេះក៏នឹងអនុញ្ញាតឱ្យប្រទេសកម្ពុជាធ្វើពិពិធកម្មកំណើន ហើយកាន់តែមានលក្ខណៈប្រកួតប្រជែងខ្លាំងឡើង។

សំខាន់ត្រូវលើកកម្ពស់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមួយដែលមានសុខភាពល្អ។ ក្នុងបណ្តាឆ្នាំកន្លងមក ប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជាបានរីកចម្រើនយ៉ាងឆាប់រហ័ស។ ខណៈពេលដែលការពង្រឹងហិរញ្ញវត្ថុធ្វើឲ្យប្រសើរឡើងនូវអន្តរការិយកម្មហិរញ្ញវត្ថុ ក៏ដូចជាទ្រទ្រង់កំណើនសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុដែលគ្មាននិរន្តរភាព ក្នុងស្ថានភាពរឹតបន្តឹងស្ថានភាពហិរញ្ញវត្ថុពិភពលោកអាចបង្កឱ្យមានអស្ថិរភាព ហើយជះឥទ្ធិពលអវិជ្ជមានមកលើវិស័យផលិតកម្មនៃសេដ្ឋកិច្ច។ ដូច្នេះ សំខាន់ត្រូវពង្រឹងការត្រួតពិនិត្យ បង្កើនសមត្ថភាព លើកកំពស់ប្រព័ន្ធជូនដំណឹងជាមុន និងប្រព័ន្ធដោះស្រាយ រួមទាំងអភិបាលកិច្ចល្អ។ បន្តលើកកំពស់ការអនុវត្តន៍ ការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ ដោយប្រើប្រាស់ប្រព័ន្ធតាមដានឯកសារនិងការតាមដានច្បាស់លាស់ សំខាន់ដើម្បីធានាអនុលោមភាពជាមួយបទប្បញ្ញត្តិ ប្រុង

ប្រយ័ត្ន បង្កលក្ខណៈឲ្យមានប្រព័ន្ធជូនដំណឹងជាមុននិងប្រព័ន្ធដោះស្រាយបញ្ហា។ បច្ចុប្បន្ន កំពុងមានការរៀបចំផែនការជំហានដំបូងដ៏ល្អ។ ជំហានទាំងនេះរួមមាន ការត្រៀមលក្ខណៈបង្កើតក្រុមគណៈកម្មាធិការគ្រប់គ្រងវិបត្តិ និងក្រុមការងារគ្រប់គ្រងវិបត្តិ ជាក្របខ័ណ្ឌមួយសម្រាប់វាយតម្លៃនិងត្រួតពិនិត្យស្ថាប័នជាប្រព័ន្ធ ដែលតម្រូវឲ្យមានយន្តការមួយសម្រាប់ជួយធនាគារ ក្នុងគ្រាធនាគារជួបបញ្ហាសាច់ប្រាក់ងាយស្រួល ឬអសាធនភាពចងក្រង សៀវភៅណែនាំស្តីពីការគ្រប់គ្រងវិបត្តិ ការរៀបចំផែនការយថាភាព និងផែនការទំនាក់ទំនង ក៏ដូចជាការធ្វើលំហាត់ប្រដូចអំឡុងពេលមានវិបត្តិ។ ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលដែលជារូបិយវត្ថុក្នុងស្រុក នឹងបង្កលក្ខណៈឲ្យធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលរបស់កម្ពុជា បំពេញមុខងារកាន់តែសំខាន់ខ្លាំងឡើងក្នុងការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ។

ក្នុងស្ថានភាពដែលសេដ្ឋកិច្ចកម្ពុជាប្រើប្រាស់ប្រាក់ដុល្លារអាមេរិកយ៉ាងច្រើន ការកសាងលំហសារពើពន្ធតាមរយៈការកែលម្អការប្រមូលចំណូលដោយពង្រីកមូលដ្ឋានគិតពន្ធ ការកែលម្អការគ្រប់គ្រងពន្ធ និងការពង្រឹងអភិបាលកិច្ចគឺជាការចាំបាច់ ត្រូវមានឧបករណ៍គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដែលមានប្រសិទ្ធិភាព ដើម្បីកាត់បន្ថយវិបត្តិនានាដែលអាចកើតមាន។

# ប្រធានបទពិសេសៈ ការតម្លើងប្រាក់បៀវត្សក្នុងវិស័យសាធារណៈ


## សង្ខេប

1. ទំហំ និងចំណាយសរុបរបស់មន្រ្តីរាជការនៃប្រទេសកម្ពុជានៅតូច បើធៀបទៅនឹងក្រុមប្រទេសដែលមានប្រាក់ចំណូលទាបដទៃទៀត។ ទោះជាយ៉ាងណាក្តី ដោយសារតែមានចំណូលក្នុងស្រុកទាប ចំណាយលើបៀវត្សរបស់ប្រទេសកម្ពុជាមានទំហំស្មើនឹង 36 ភាគរយនៃប្រាក់ចំណូលក្នុងស្រុក (ឆ្នាំ 2012) ជាចំណែកមួយដែលមានកម្រិតខ្ពស់។
2. ការបង្កើនប្រាក់បៀវត្សឆ្នាំ 2014 គឺមានកម្រិតល្មមនៅឡើយ និងត្រូវបានប៉ាន់ស្មានថាត្រូវចំណាយបន្ថែមចំនួន 42 លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ ។ ប្រាក់នេះគឺដើម្បីបង្កើនប្រាក់ខែមូលដ្ឋានរបស់មន្រ្តីរាជការស៊ីវិលប្រភេទ ខ គ និង ឃ (ទាបបំផុត)ចំនួន 80,000 រៀល ក្នុងមួយខែ និងប្រភេទ ក (ខ្ពស់បំផុត) ចំនួន 40.000 រៀល ក្នុងមួយខែ។ បៀវត្សមូលដ្ឋានមធ្យមប្រភេទ ឃ ឥឡូវនេះគឺ 344.371 រៀលឬ 86 ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ។
3. ការកើនឡើងនូវបន្ទុកចំណាយលើប្រាក់បៀវត្សបន្ថែមសម្ពាធដែលអាចបន្ថយចំណាយចាំបាច់ផ្នែកថែទាំដែលកំពុងថយចុះបើគិតជាចំណែកនៃចំណាយវិនិយោគ ហើយក៏មិនធានាថាធ្វើអោយប្រសើរឡើងនៃការផ្តល់សេវាសាធារណៈ។ ហេតុនេះ ការបង្កើនឡើងនូវប្រាក់បៀវត្សគប្បីដើរទន្ទឹមគ្នាជាមួយនឹងការលើកកំពស់ការគ្រប់គ្រងធនធានមនុស្សក្នុងការដោះស្រាយលទ្ធផលអនុវត្តការងារ ការដាក់ពង្រាយមន្រ្តីរាជការ និងវិភាជន៍ថវិកាតាមវិស័យដែលប្រសើរបំផុត។


## ទំហំមុខងារសាធារណៈរបស់ប្រទេសកម្ពុជា

**មុខងារសាធារណៈ(ស៊ីវិល) នៅកម្ពុជាមានទំហំតូចគឺមានមន្ត្រីរាជការប្រមាណជា 1,4 នាក់ ក្នុងចំនួនប្រជាជនមួយរយនាក់។** តួលេខនេះមានកម្រិតទាបជាងបណ្តាប្រទេសភាគច្រើននៅក្នុងតំបន់ (រូបភាពទី 1) ទោះបីជាចំនួននេះបានកើន 28 ភាគរយ ក្នុងអំឡុងមួយទសវត្សរ៍កន្លងមកក្តី និងកើនឡើងចំនួន 47 ភាគរយក្នុងអំឡុងពីរទសវត្សមកនេះ (រូបទី 2) ។

*មន្ត្រីរាជការស៊ីវិលកម្ពុជានៅមានចំនួនតិច...*

**រូបលេខ 1: ការប្រៀបធៀបជាអន្តរជាតិនៃទំហំវិស័យសាធារណៈ:**
(ក្នុងប្រជាជន100នាក់)




ប្រភព:ការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងវិទ្យាស្ថានជាតិស្ថិតិ

*ទោះបីជាមានកំណើនយ៉ាងខ្ពស់នៅឆ្នាំ 2008 ក្តី*

**រូបលេខ 2: ចំនួនមន្ត្រីរាជការកម្ពុជា**




ប្រភព:ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

*ជាចំណែកនៃ ផសស បញ្ជីប្រាក់ខែសរុបនៅមានទំហំតូចនៅឡើយ...*

**រូបលេខ 3: បញ្ជីប្រាក់ខែនិង ផសស ក្នុងពលរដ្ឋម្នាក់ៗ**




ប្រភព:World Development Indicators, ធនាគារពិភពលោក និងរបាយការណ៍ប្រចាំប្រទេស មូលនិធិរូបិយវត្ថុអន្តរជាតិ

*ប្រាក់ខែអប្បរមារបស់មន្ត្រីរាជការ(ស៊ីវិល)កម្ពុជាមានកម្រិតទាប*

**រូបលេខ4: ប្រាក់ខែអប្បរមារបស់មន្ត្រីរាជការ:ការប្រៀបធៀបក្នុងតំបន់**
(ដុល្លារអាមេរិកក្នុងមួយខែ)




ប្រភព:ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងការវិភាគរបស់ធនាគារពិភពលោក

## ចំណាយមុខងារសាធារណៈរបស់កម្ពុជា

**ចំណាយបៀវត្សសរុបរបស់ប្រទេសកម្ពុជា ដែលគិតជាចំណែកនៅផសស នៅមិនខ្ពស់ណាស់ទេ បើប្រៀបធៀប នឹងប្រទេសចំណូលទាបផ្សេងៗទៀត។** ចំណាយបៀវត្សសរុប (ស៊ីវិល សន្តិសុខ និងយោធា) ចំនួន5,5ភាគរយនៃផសស ដូចដែលបានថែងក្នុងថវិកាឆ្នាំ2014 មិនខ្ពស់ពេកទេ បើប្រៀបធៀបនឹងប្រទេសនានាដែលមានកំរិតចូលសំរាប់ប្រជាជន ម្នាក់ៗ ប្រហាក់ប្រហែល(រូបទី3)។[21]

ទោះបីជាមានការលំបាកក្នុងការប្រៀបធៀបដោយនិយមន័យនៃប្រាក់បៀវត្សផ្សេងៗគ្នាប្រើប្រាស់ក្នុងប្រទេសផ្សេងគ្នា ការប្រៀបធៀបជាមួយប្រទេសក្នុងតំបន់ដែលមានកម្រិតចំណូលរបស់មនុស្សម្នាក់ៗប្រហាក់ប្រហែលកម្ពុជា បង្ហាញថា បៀវត្សអប្បបរមារបស់មន្ត្រីរាជការកម្ពុជាមានកម្រិតទាបជាងរបស់មន្ត្រីរាជការឡាវ និងមីយ៉ាន់ម៉ា ប៉ុន្តែខ្ពស់ជាងបៀវត្សមន្ត្រីរាជការវៀតណាម (រូបលេខ 4) ។ ស្រដៀងគ្នានឹងប្រទេសកម្ពុជាដែរ បណ្តាប្រទេសនានានៅក្នុងតំបន់កំពុងខិតខំប្រឹងប្រែងបង្កើនបៀវត្សអប្បបរមាសម្រាប់មន្ត្រីរាជការរបស់ខ្លួន។ ប្រទេសទាំងនេះរួមមាន ទោះជាយ៉ាងណាក្តី ប្រទេសកម្ពុជាកំពុងប្រឈមមុខនឹងឧបសគ្គដែលតែងកើតមានជាទូទៅ ពោលគឺថាកម្រិតនៃការប្រមូលចំណូលក្នុងស្រុកធ្វើឲ្យលទ្ធភាពបើកប្រាក់បៀវត្សឲ្យមន្ត្រីរាជការកាន់តែមានកម្រិត។

**ទោះបីជាចំណាយបៀវត្សសរុបរបស់កម្ពុជាចំពោះថវិកាឆ្នាំ 2014 មានកម្រិតខ្ពស់ បើគិតភាគរយនៃចំណាយចរន្ត និងចំណូលក្នុងស្រុក ប្រៀបធៀបជាមួយបណ្តាប្រទេសមានប្រាក់ចំណូលទាបក្នុងតំបន់នេះគឺដោយសាកម្រិតចំណាយចរន្ត និងចំណូលក្នុងស្រុករបស់កម្ពុជានៅទាប** (រូបទី 5 និងរូបភាពទី6) ។ ទោះបីជាកាលពីពេលថ្មីនេះ លទ្ធផលប្រមូលប្រាក់ចំណូលបានកើនឡើងក្តី អនុបាតចំណូលធៀបនឹងផសសនៅទាបនៅឡើយ។ ចំណាយចរន្តរបស់កម្ពុជា ជាពិសេសគឺចំណាយមិនមែនបៀវត្សដែលនៅតែត្រូវបានត្បិតត្បៀត។

## ការពង្រាយមន្ត្រីរាជការ និងការវិភាជថវិកាប្រាក់បៀវត្សតាមវិស័យ

**អទិភាពតាមវិស័យក្នុងការពង្រាយមន្ត្រីរាជការនៅតែមានភាពសមស្រប។** ចំនួនសរុបបង្ហាញថា វិស័យសង្គមកិច្ចរួមទាំងសុខាភិបាល និងអប់រំនៅតែបានទទួលចំណែកធំបំផុតនៃចំនួនមន្ត្រីរាជការ (រូបទី7)។

**ប៉ុន្តែវិភាជថវិកាតាមវិស័យមិនផ្តល់អទិភាពដល់វិស័យសង្គមកិច្ចទេ មិនដូចការពង្រាយមន្ត្រីរាជការ។** ខណៈដែល ចំនួនមន្ត្រីរាជការធ្វើការនៅក្នុងវិស័យសង្គមកិច្ចគ្មានការប្រែប្រួល (ឬកើនឡើងបន្តិច) ប្រមាណជាបីភាគបួននៃមន្ត្រីរាជការទាំងអស់ ចំណែកនៃការចំណាយប្រាក់បៀវត្សដែលបានវិភាជទៅកាន់វិស័យសង្គមកិច្ចក្នុងបញ្ជីប្រាក់ខែសរុបរបស់មន្ត្រីរាជការស៊ីវិល ជាពិសេសសម្រាប់វិស័យអប់រំ ថយចុះមកត្រឹមតែ 44 ភាគរយ នៅឆ្នាំ 2013 ធៀបនឹងកម្រិតខ្ពស់បំផុតចំនួន 57 ភាគរយ នៅក្នុងឆ្នាំ 2001 (រូបលេខ 8) ។ ប្រការនេះមានន័យថាលាភការមេធ្យមនៅក្នុងវិស័យអប់រំមាននិន្នាការធ្លាក់ចុះ។

---

[21] ចំណាយបៀវត្សខាងរួមបញ្ចូលគ្រប់ចំណាយបុគ្គលិកទាំងអស់រួមទាំងចំណាយឧបត្ថម្ភ។




## របាយមន្ត្រីរាជការនិងថវិកានៅថ្នាក់ខេត្តនិងនៅថ្នាក់កណ្តាល

**របាយមន្ត្រីរាជការគឺផ្តោតទៅលើថ្នាក់កណ្តាល។** ទិន្នន័យសរុបស្តីពីទំហំនៃមុខងារសាធារណៈក៏បិទបាំងបញ្ហាមួយចំនួនជុំវិញរបាយនៃមន្ត្រីរាជការស៊ីវិលតាមភូមិសាស្ត្រផងដែរ។ មានភស្តុតាងបង្ហាញថាប្រាក់ខែទាបនិងអវត្តមាននៃឱកាស "ធ្វើការក្រៅ" នៅតាមបណ្តាខេត្តនានាជម្រុញឱ្យមន្ត្រីរាជការទៅធ្វើការនៅតាមទីក្រុងនិងទីរួមខេត្តនានា។ កត្តាសង្គម និងវប្បធម៌ក៏រួមចំណែកអោយមានមន្ត្រីរាជការប្រមូលផ្តុំច្រើននៅថ្នាក់កណ្តាលរួមទាំងកង្វះនៃភាពទាក់ទាញ ពេលធ្វើការនៅតំបន់ជនបទ។ នេះជាហេតុធ្វើឲ្យការផ្តល់សេវានៅតំបន់ជនបទនៃបណ្តាខេត្តដែលជាកន្លែងប្រជាជនកម្ពុជាភាគច្រើនកំពុងរស់នៅមិនបានគ្រប់គ្រាន់។

**ចំនួនមន្ត្រីរាជការដែលបម្រើការនៅថ្នាក់ខេត្ត ក្នុងវិស័យជនបទសំខាន់ៗមួយចំនួន ដូចជាកសិកម្មអភិវឌ្ឍជនបទនិងបរិស្ថានក៏ដូចជាសាធារណការ ជាទូទៅបានធ្លាក់ចុះចាប់ពីឆ្នាំ 2007 មក** (រូបលេខ 9) ។ ការផ្តោតអារម្មណ៍កាន់តែខ្លាំងរបស់មន្ត្រីរាជការនៅថ្នាក់កណ្តាលចំពោះវិស័យជនបទទាំងនេះ មិនទំនងជាមានលក្ខណៈវិជ្ជមានសម្រាប់ការពង្រីកលទ្ធភាពទទួលបានសេវាសាធារណៈប្រកបដោយសមធម៌ឡើយ។ ចំណែកជាភាគរយនៃថវិកាខេត្តក្នុងថវិកាសរុបសំរាប់វិស័យសង្គមកិច្ច និងវិស័យជនបទដែលបង្ហាញ

ក្នុងតារាងលេខ 2 កំពុងថយចុះដោយសារកំណើននៃថវិកាខេត្តមានភាពយឺតជាងច្រើន បើប្រៀបធៀបទៅនឹង កំណើននៃថវិកាសរុបរបស់វិស័យទាំងនោះ។

**អាចតម្រូវឲ្យមានពិនិត្យឡើងវិញអំពីផែនការចំណាយប្រតិបត្តិការនិងចំណាយសាធារណៈជនគោលដៅ (PER)** ។ ការធ្វើ PERs អាចជួយផ្ដល់ពន្លឺខ្លះអំពីការថយចុះចំនួនមន្ត្រីរាជការធ្វើការនៅថ្នាក់ខេត្តរួមជាមួយនឹងការថយចុះចំណែកនៃថវិកាដែលបានវិភាជទៅកាន់ថ្នាក់ខេត្តនេះ។

**មានការផ្លាស់ប្ដូរពីប្រភេទកម្រិតបៀវត្សរ៍ទាបទៅខ្ពស់។** ចំនួនមន្ត្រីរាជការប្រភេទ គ និង ឃ ក្នុងចំណោមមន្ត្រីរាជការសរុបបានធ្លាក់ចុះប្រហែល 9 ភាគរយ ពី 55,8 ភាគរយ នៅឆ្នាំ 2009 ដល់ 46,9 ភាគរយ នៅឆ្នាំ 2014 ខណៈដែលមន្ត្រីរាជការប្រភេទប្រភេទ ក និង ខ បានកើនឡើង (រូបលេខ 10) ។ នេះអាចជានិន្នាការមានស្ថានភាពល្អ ជាសញ្ញានៃការធ្វើឲ្យមុខងារសាធារណៈមានលក្ខណៈអាជីព។ ទោះជាយ៉ាងណាក្ដី ស្ថានភាពនេះក៏អាចបញ្ជាក់អំពី សមាមាត្រមិនសមរម្យរវាងបុគ្គលិកគាំទ្រនិងបុគ្គលិកបច្ចេកទេស/ជំនាញ។ ការពិនិត្យមុខងារឡើងវិញ អាចជួយកំណត់ថាតើនេះជាករណីសមាមាត្រមិនសមរម្យឬយ៉ាងណាសំរាប់ទទួលបានប្រសិទ្ធភាពខ្ពស់បំផុត។

*ចំណែកភាគរយនៃបុគ្គលិកថ្នាក់ខេត្តក្នុងវិស័យជនបទក៏ធ្លាក់ចុះ*

**រូបលេខ 9: ចំនួនមន្ត្រីរាជការថ្នាក់ខេត្ត**
(គិតជាភាគរយនៃចំនួនសរុប)




ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

*ចំណែកភាគរយនៃថវិកាខេត្តក៏ធ្លាក់ចុះដែរ*

តារាងលេខ 2: ការពង្រាយមន្ត្រីរាជការស៊ីវិល

| | ថវិកាសរុបនិងថវិកាខេត្ត | បំរែបំរួលឆ្នាំ 2914 ធៀបនឹងឆ្នាំ 2009 | |
|---|---|---|---|
| | | លានរៀល | ភាគរយ |
| 1 | **វិស័យសុខាភិបាល** | **473,804.7** | **94.0%** |
| | *ក្នុងនោះ ថ្នាក់ខេត្ត* | *126,703.3* | *78,7%* |
| 2 | **អប់រំ យុវជន និងកីឡា** | **599,503.0** | **80.7%** |
| | *ក្នុងនោះ ថ្នាក់ខេត្ត* | *451,638.3* | *88.0%* |
| 3 | **បរិស្ថាន** | **11,540.7** | **59.1%** |
| | *ក្នុងនោះ ថ្នាក់ខេត្ត* | *4,649.1* | *57.8%* |
| 4 | **កសិកម្មរុក្ខាប្រមាញ់និងនេសាទ** | **80,232.0** | **101.6%** |
| | *ក្នុងនោះ ថ្នាក់ខេត្ត* | *12,952.3* | *45.9%* |
| 5 | **អភិវឌ្ឍន៍ជនបទ** | **163,898.0** | **257.1%** |
| | *ក្នុងនោះ ថ្នាក់ខេត្ត* | *12,479.6* | *62.4%* |
| 6 | **សាធារណៈការនិងដឹកជញ្ជូន** | **275,526.9** | **869.6%** |
| | *ក្នុងនោះ ថ្នាក់ខេត្ត* | *15,877.1* | *84.1%* |
| 7 | **ធនធានទឹកនិងឧតុនិយម** | **150,060.4** | **478.6%** |
| | *ក្នុងនោះ ថ្នាក់ខេត្ត* | *8,510.6* | *67.6%* |

ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

*ចំណែកប្រភេទថ្នាក់ក្រោមថយចុះ...*

**រូបលេខ 10: មន្ត្រីរាជការស៊ីវិលតាមប្រភេទប្រាក់ខែ**
(ភាគរយនៃចំនួនសរុប)




ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

*ចំណាយសម្រាប់ថែទាំមិនអាចតាមទាន់ការវិនិយោគ*

**រូបលេខ 11: ចំណាយប្រតិបត្តិការនិងថែទាំ**
(ភាគរយនៃចំណាយមូលធន)




ប្រភព: ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ជាការសំខាន់ណាស់ក្នុងការធានាបាននូវថវិកាប្រតិបត្តិការ និងថែទាំ (O & M) គ្រប់គ្រាន់ក្នុងគោលបំណងរក្សាបាននូវធនធានមូលធនសមស្រប។** ការកើនឡើងនូវវិនិយោគសាធារណៈជាតួលេខដាច់ខាតនិងជាភាគរយនៃផលិតផលក្នុងស្រុកសរុបក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធធារាសាស្ត្រ ផ្គត់ផ្គង់ទឹក និងបណ្តាញបញ្ជូនថាមពលអគ្គិសនី ដែលឧបត្ថម្ភគាំទ្រភាគច្រើនដោយដៃគូអភិវឌ្ឍន៍ បានចូលរួមចំណែកក្នុងការបង្កើនធនធានមូលធន។ ទោះជាយ៉ាងណាក្តី ថវិកាសម្រាប់សម្ភារៈនិងបរិក្ខារ ក៏ដូចជាថវិកាសម្រាប់ប្រតិបត្តិការនិងថែទាំ ជាភាគរយនៃចំណាយដើមទុនសរុប បានធ្លាក់ចុះចាប់តាំងពីឆ្នាំ 2008 មក (រូបលេខ11) [22]។ នេះគឺជាបញ្ហាដែលនឹងត្រូវដោះស្រាយតទៅមុខ។បញ្ហានេះតំរូវអោយមានការយកចិត្តដាក់ឆ្ពោះទៅមុខដែលត្រូវធ្វើអោយថ្លឹងថ្លែងអោយបានសមស្របរវាងការកើនឡើងនៃប្រាក់បៀវត្ស និងចំណាយអទិភាពផ្សេងៗរួមទាំងចំណាយថែទាំ និងដំណើរការ។

## ការតម្លើងប្រាក់បៀវត្សឆ្នាំ 2014

**តារាងលេខ ៣: ចំណាយប៉ាន់ស្មាននៃថវិកាបន្ថែមសម្រាប់ការតម្លើងប្រាក់ខែក្នុងឆ្នាំ2014**

| ប្រភេទ | ចំណាត់ថ្នាក់ | ប្រាក់ខែមូលដ្ឋានជាមធ្យមប្រចាំខែ | | តួលេខប៉ាន់ស្មានចំនួនមន្ត្រីរាជការអចិន្ត្រៃយ៍ | កំណើនប្រាក់ខែមូលដ្ឋានសម្រាប់ឆ្នាំ 2014 | | ប្រាក់ខែមូលដ្ឋានជាមធ្យមប្រចាំខែ | | | តម្រូវការថវិកាបន្ថែមប្រចាំឆ្នាំ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | រៀល | គិតជាដុល្លារ | | រៀល | គិតជាដុល្លារ | រៀល | គិតជាដុល្លារ | បំរែបំរួលគិតជា% | រៀល | គិតជាដុល្លារ |
| A | A1 | 749,613 | 187 | 345 | 40,000 | 10 | 789,613 | 197 | 5 | 165,800,727 | 41,450 |
| | A2 | 648,280 | 162 | 1,612 | 40,000 | 10 | 688,280 | 172 | 6 | 773,736,727 | 193,434 |
| | A3 | 561,066 | 140 | 36,039 | 40,000 | 10 | 601,066 | 150 | 7 | 17,298,542,545 | 4,324,636 |
| B | B1 | 530,733 | 133 | 2,414 | 80,000 | 20 | 610,733 | 153 | 15 | 2,317,314,712 | 579,329 |
| | B2 | 453,568 | 113 | 3,673 | 80,000 | 20 | 533,568 | 133 | 18 | 3,526,348,475 | 881,587 |
| | B3 | 373,269 | 93 | 55,834 | 80,000 | 20 | 453,269 | 113 | 21 | 53,600,496,814 | 13,400,124 |
| C | C1 | 362,520 | 91 | 860 | 80,000 | 20 | 442,520 | 111 | 22 | 825,962,127 | 206,491 |
| | C2 | 309,472 | 77 | 765 | 80,000 | 20 | 389,472 | 97 | 26 | 734,188,557 | 183,547 |
| | C3 | 271,971 | 68 | 73,897 | 80,000 | 20 | 351,971 | 88 | 29 | 70,940,969,316 | 17,735,242 |
| D | | 264,371 | 66 | 16,024 | 80,000 | 20 | 344,371 | 86 | 30 | 15,383,040,000 | 3,845,760 |
| | | | សរុប | 191,463 | | | | សរុប | | **165,566,400,000** | **41,391,600** |

ប្រភព: MEF, MCS, ការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

- **ថវិកាឆ្នាំ2014ប្រមើលឃើញនូវការកើនឡើងនូវបញ្ជីប្រាក់បៀវត្សសរុបពី 40 ទៅ 45 ភាគរយនៃចំណាយចរន្ត។** កំណើននេះមានទំហំប្រហែល 0.5 ភាគរយ នៃផសស គឺកើនឡើងពី 5.0 ភាគរយ នៅឆ្នាំ 2013 ដល់ 5.5 ភាគរយ នៅឆ្នាំ2014។

[22] ចំណាយសម្ភារៈ បរិក្ខារ ប្រតិបត្តិការនិងថែទាំស្ថិតនៅក្នុងជំពូក 60 និង 61 នៃចំណាត់ថ្នាក់ថវិកាបច្ចុប្បន្ន

- **មានកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើនប្រាក់ខែគោលសម្រាប់មន្ត្រីរាជការស៊ីវិលចំនួន 80,000 រៀល សម្រាប់ប្រាក់ខែប្រភេទ ឃ (ទាបបំផុត) គ និង ខ និង 40.000 រៀល សម្រាប់ប្រាក់ខែប្រភេទ ក** [23]។ ជាទំហំទឹកប្រាក់កំណើនប្រាក់ខែនេះត្រូវបានគេប៉ាន់ស្មានថានឹងមានចំនួនប្រហែល 166 ពាន់លានរៀល ឬសមមូលនឹង 42 លានដុល្លារអាមេរិក (តារាងលេខ3)។

- **ការព្យាករណ៍ខាងលើមិនរាប់បញ្ចូលអថេរនានាដូចជាការបន្ថែមម៉ោងដែលនឹងកើនឡើងដោយសារការតម្លើងប្រាក់ខែគោលឡើយ។** ម៉ោងបន្ថែមភាគច្រើនត្រូវបានទូទាត់ឱ្យគ្រូបង្រៀនប្រមាណជា 5 ភាគរយបញ្ជីប្រាក់ខែសរុប[24]។ ដូច្នេះ គិតទាំងម៉ោងបន្ថែម បញ្ជីប្រាក់ខែសរុបកើនឡើងដោយសារការតម្លើងប្រាក់ខែ មូលដ្ឋានសម្រាប់ឆ្នាំ 2014 ដែលអាចឈានដល់ប្រមាណជា 44 លានដុល្លារអាមេរិក[25]។

- **កំណើននៃចំណាយប្រាក់បៀវត្សក្នុងថវិកាឆ្នាំ2014 បានស្រូបយកទាំងស្រុងនូវចំណូល បន្ថែមដែលរំពឹងថានឹងទទួលបានក្នុងឆ្នាំ ដោយមិនបានទុកលទ្ធភាពអោយចំណាយមិនមែនប្រាក់បៀវត្សធៀបនឹងផសសកើនឡើង។** កំណើននៃចំណាយប្រាក់បៀវត្សស្រូបយកថវិកាចំណូលដែលកើនឡើងគឺប្រមាណ 0,5ភាគរយនៃផសសនៅក្នុងឆ្នាំ2014។ ចំណាយមិនមែនប្រាក់បៀវត្សធៀបនឹងផសស ចិតនៅតែ 6,5ភាគរយ ប្រហាក់ប្រហែលនឹងឆ្នាំ2013ដែរ។ ដូចនេះក៏មិនទុកលទ្ធភាពអោយមានការកើនឡើងនៃចំណែករបស់ថវិការសំរាប់ការថែទាំ និងប្រតិបត្តិការ និងចំណាយសង្គមកិច្ចគិតជាភាគរយ នៃផសស។

## សេចក្តីសន្និដ្ឋាន

- **បទពិសោធន៍អន្តជាតិចង្អុលបង្ហាញពីការសារៈសំខាន់នៃការកំណត់នយោបាយចំណាយប្រាក់បៀវត្សសំរាប់វិស័យសាធារណៈ ដែលជាផ្នែកមួយចាំបាច់នៃកំណែទម្រង់មុខងារសាធារណៈដែលរួមទាំងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស។** កត្តាសំខាន់ៗ នៃកំណែទម្រង់នេះមាន ការគ្រប់គ្រងផ្ទៃក្នុងរឹងមាំដើម្បីធានាប្រសិទ្ធ ធ្វើអោយប្រាក់បៀវត្សមានភាពសមស្រប ដោយដំបូលឡើងដាក់ប្រាក់ដំណាច់ផ្សេងៗបញ្ចូលក្នុងបៀវត្សមូលដ្ឋាន។ ការតម្លើងប្រាក់បៀវត្ស ដែលអនុវត្តកន្លងទៅផ្អែកលើមូលដ្ឋាននៃការតម្លើងដែលមានសមាមាត្រដូចគ្នា ជាមួយនឹងការកែទម្រង់តិចតួចចំពោះការចាត់ចែង និងការអភិវឌ្ឍធនធានមនុស្ស ហាក់ដូចជាមិនបានធ្វើអោយប្រសើរឡើងការផ្តល់សេវាសាធារណៈ។

---

[23] អនុក្រឹត្យលេខ 1 ចុះថ្ងៃទី 2 ខែមករា ឆ្នាំ 2014 ។ ទោះជាយ៉ាងណាក្តី ការតម្លើងប្រាក់ខែគោល មិនគ្របដណ្តប់មន្ត្រីរាជការបម្រើការនៅតាមអង្គភាព ស្ថាប័ន និងអាជ្ញាធរនីតិកម្ម តុលាការ ប្រឆាំងអំពើពុករលួយនៅថ្នាក់ជាតិឡើយ។ ប្រាក់ខែគោលមិនបានរួមបញ្ចូលប្រាក់អត្ថប្រយោជន៍និងប្រាក់ឧបត្ថម្ភ ដូចជាប្រាក់ឧបត្ថម្ភមុខងារដែលមានចំនួនពីរបីដងសម្រាប់ប្រាក់ខែប្រភេទខ្ពស់។

[24] បញ្ជីប្រាក់ខែក៏រួមមានប្រាក់អត្ថប្រយោជន៍និងប្រាក់ឧបត្ថម្ភផ្សេងៗដូចជាការប្រាក់ឧបត្ថម្ភមុខងារ ដែលទឹកប្រាក់មានចំនួនដល់ទៅ 15 ភាគរយនៃបញ្ជីប្រាក់ខែសរុប។

[25] ឧបមាថាជាមធ្យមការធ្វើការបន្ថែមម៉ោងក្នុងមួយខែស្មើនឹង 40 ម៉ោងដោយមន្ត្រីរាជការស៊ីវិលចំនួន 80,000 នាក់ ដែលភាគច្រើនជាគ្រូបង្រៀនប្រភេទ ក ការបង្កើនចំណាយទូទាត់ដែលបានអនុម័តក្នុងឆ្នាំ 2014 ត្រូវបានប៉ាន់ស្មានថាមានចំនួន 2,4 លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។

- **ជំហានបន្ទាប់ដែលជួយផ្ដល់នយោបល់ដល់គោលនយោបាយប្រាក់បៀវត្សរបស់រដ្ឋាភិបាលរួមមាន៖**
  - ការអង្កេតបៀវត្សដែលពិនិត្យមើល និងប្រៀបធៀបការផ្ដល់ប្រាក់បៀវត្សនៃវិស័យសាធារណៈ ជាមួយក្រុមហ៊ុនឯកជន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនពហុជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានាក្នុងស្រុក។
  - ការពិនិត្យមើលលើនិតិវិធីផ្ទៃក្នុង ការអនុវត្តកិច្ចការគ្រប់គ្រងចំពោះមុខងារ និងការបំពេញការងារ និងការផ្ដល់ប្រព័ន្ធវិភាគដ៏រឹងមាំសម្រាប់កំណែទម្រង់មុខងារសាធារណៈ។

# ឧបសម្ព័ន្ធ:សូចនាករសំខាន់ៗនៅប្រទេសកម្ពុជា

| | ឆ្នាំ 2011 | ឆ្នាំ 2012 | ឆ្នាំ 2013e | ឆ្នាំ 2014p | ឆ្នាំ 2015f | ឆ្នាំ 2016f |
|---|---|---|---|---|---|---|
| **លទ្ធផល ការងារ និងថ្លៃ** | | | | | | |
| ផលិតផលក្នុងស្រុកសរុបពិត (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 7.1 | 7.3 | 7.4 | 7.2 | 7.0 | 7.0 |
| តម្រូវការក្នុងស្រុក (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 1.0 | 11.9 | 8.5 | 9.7 | 10.2 | 11.0 |
| សន្ទស្សន៍ផលិតកម្មឧស្សាហកម្ម )ឆ្នាំ 2000 = 100) | 300.8 | 315.9 | 341.1 | 368.4 | 396.1 | 420.0 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 14.5 | 5.0 | 8.0 | 8.0 | 7.5 | 6.0 |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 4.9 | 2.5 | 4.7 | 5.0 | 5.5 | 6.0 |
| **វិស័យសាធារណៈ** | | | | | | |
| ប្រាក់ចំណូលរដ្ឋាភិបាល (% ផសស) | 13.2 | 15.3 | 14.8 | 15.0 | 15.0 | 15.2 |
| ការចំណាយរដ្ឋាភិបាល(% ផសស) | 22.8 | 21.0 | 21.3 | 20.3 | 20.0 | 20.0 |
| តុល្យភាពចណ/ចណរដ្ឋាមិនគិតជំនួយឥតសំណង (% ផសស) | -9.6 | -5.7 | -6.5 | -5.3 | -5.0 | -4.8 |
| តុល្យភាពចណ/ចណរដ្ឋាគិតទាំងជំនួយឥតសំណង (% ផសស) | -4.6 | -3.3 | -3.9 | -3.2 | -3.5 | -3.3 |
| **ជញ្ជីងពាណិជ្ជកម្ម ជញ្ជីងទូទាត់និងបំណុលបរទេស** | | | | | | |
| ជញ្ជីងពាណិជ្ជកម្ម (លានដុល្លាអាមេរិក) | -1,490.0 | -1,949.2 | -1,983.9 | -2,096.2 | -2,508.9 | -2,793.0 |
| ការនាំចេញទំនិញ (លានដុល្លាអាមេរិក) | 5,219.5 | 6,015.7 | 6,777.5 | 7,979.4 | 9,229.2 | 10,705.8 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 34.4 | 15.3 | 12.7 | 17.7 | 15.7 | 16.0 |
| ការនាំចេញសំខាន់ៗ (% ប្រែប្រួលធៀបនឹងឆ្នាំមុន)1 / | 31.7 | 7.0 | 17.6 | 17.5 | 15.5 | 15.0 |
| ការនាំចូលទំនិញ (លានដុល្លាអាមេរិក) | 6,709.5 | 7,964.9 | 8,761.4 | 10,075.6 | 11,738.1 | 13,498.8 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 22.7 | 18.7 | 10.0 | 15.0 | 16.5 | 15.0 |
| តុល្យភាពគណនីចរន្ត (លានដុល្លារអាមេរិក) 2/ | -1,014.9 | -1,436.6 | -1,450.9 | -1,620.1 | -1,824.9 | -2,119.6 |
| (% នៃផលិតផលក្នុងស្រុកសរុប) | -7.9 | -10.1 | -9.4 | -9.7 | -10.0 | -10.3 |
| វិនិយោគផ្ទាល់ពីបរទេស(លានដុល្លាអាមេរិក) | 785.4 | 1,410.2 | 1,200.0 | 1,230.0 | 1,450.0 | 1,520.0 |
| បំណុលបរទេស (លានដុល្លាអាមេរិក) | 3,840.8 | 4,486.0 | 5,052.0 | 5,559.4 | 5,948.7 | 6,310.9 |
| (% នៃផលិតផលក្នុងស្រុកសរុប) | 29.9 | 31.6 | 32.6 | 33.2 | 32.5 | 30.8 |
| បំណុលរយៈពេលខ្លី (លានដុល្លាអាមេរិក) | - | - | - | - | - | - |
| អនុបាតសេវាបំណុល (%នៃការនាំចេញទំនិញនិងសេវា) | 1.2 | 1.1 | 1.5 | 1.6 | 1.5 | 1.8 |
| ទុនបំរុងរូបិយប័ណ្ណបរទេសដុល (លានដុល្លាអាមេរិក) | 3,031.6 | 3,463.0 | 3,642.5 | 3,879.3 | 4,267.2 | 4,608.6 |
| (ចំនួនខែនៃការនាំចូលទំនិញនិងសេវា) | 3.4 | 3.1 | 3.8 | 3.5 | 3.4 | 3.3 |
| **ទីផ្សារហិរញ្ញវត្ថុ** | | | | | | |
| ឥណទានក្នុងស្រុក (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 37.3 | 29.6 | 28.5 | 26.0 | 25.2 | 24.8 |
| អត្រាការប្រាក់រយៈពេលខ្លី (% ក្នុងមួយឆ្នាំ ) | 15.0 | 13.7 | 13.0 | 13.0 | 12.5 | 12.2 |
| អត្រាប្តូរប្រាក់ )ប្រាក់រៀល / ដុល្លាអាមេរិក-ចុងគ្រា) | 4,039 | 3,995 | 4,000 | 4,065 | 4,076 | 4,100 |
| អត្រាប្តូរប្រាក់ពិត (2000 = 100) | 124.8 | 128.6 | 131.0 | 132.9 | 134.7 | 136.9 |
| (% ប្រែប្រួលធៀបនឹងឆ្នាំមុន) | 1.9 | 3.0 | 1.8 | 1.5 | 1.3 | 1.7 |
| | 12,828 | 14,196 | 15,491 | 16,722 | 18,291 | 20,486 |

ប្រភព:ប្រភពទិន្នន័យជាតិ មូលនិធិរូបិយវត្ថុអន្តរជាតិ និងតួលេខប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

e = ប៉ាន់ស្មាន
f = ព្យាករណ៍
p = ព្យាករណ៍(គណនា)
1/ សម្លៀកបំពាក់
2/ មិនគិតបង្វែរផ្លូវការ

The World Bank

Cambodia Country Office
113 Norodom Blvd.,
Phnom Penh, Cambodia
Tel : (855-23) 861 300
Fax : (855-23) 861 301/302
Website: www.worldbank.org